# របាយការណ៍ស្រាវជ្រាវស្តីពីបណ្តាញ និង ឫសគល់នៃអំពើជួញដូរមនុស្សនៅក្នុង ព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ការបដិសេធន៍ទទួលខុសត្រូវ:** ការសិក្សាស្រាវជ្រាវនេះ អាចប្រព្រឹត្តទៅបានដោយមានជំនួយដ៏សប្បុរសរបស់ពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ។ ខ្លឹមសារនៅក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវរបស់អង្គការវីនរ៉ក់អន្តរជាតិ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍអន្តរជាតិ ឬទស្សនៈរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# មាតិកា


មាតិកា.......... i

សេចក្តីថ្លែងអំណរគុណ.......... iii

សេចក្តីសង្ខេបនិងអនុសាសន៍.......... 1

សាវតារនិងវិធីសាស្ត្រ.......... 8

ព័ត៌មានក្រុមគោលដៅ.......... 13

ការយល់ដឹងនិងបទពិសោធន៍ជាមួយអំពើជួញដូរមនុស្ស.......... 17

ក្របខ័ណ្ឌការវាយតម្លៃជាលក្ខណៈចក្ខុវិស័យ.......... 20

ការវាយតម្លៃភាពងាយរងគ្រោះ.......... 24

ការបែងចែកភាពងាយរងគ្រោះ.......... 31

ជំនឿស៊ុប.......... 36

ខ្សែចង្វាក់ផ្គត់ផ្គង់និងកត្តាគន្លឹះបង្កហានិភ័យ..........40

**ឧបសម្ព័ន្ធ** 1

កម្រងសំណួរសំរាប់សម្ភាសន៍ពីខ្សែចង្វាក់ផ្គត់ផ្គងអំពើជួញដូរមនុស្ស..........50

**ឧបសម្ព័ន្ធ** 2

កម្រងសំណួរសំរាប់សម្ភាសន៍ពីភាពងាយរងគ្រោះ..........68

**ឧបសម្ព័ន្ធ** 3

មណ្ឌលដែលបានចូលរួម.......... 83

**ឧបសម្ព័ន្ធ** 4

បញ្ជីរាយនាមអ្នកពាក់ពន្ធ័នានា.......... 84

**ឧបសម្ព័ន្ធ** 5

បញ្ជីឯកសារយោង.......... 85

# សេចក្តីថ្លែងអំណរគុណ

អង្គការវីនរ៉ក់អន្តរជាតិ សូមថ្លែងអំណរគុណចំពោះលោក លោកស្រីទាំងអស់ដែលបានចូលរួម និង ជួយសម្របសម្រួលដល់ដំណើរការនៃការសិក្សាស្រាវជ្រាវនេះប្រកបដោយភាពជោគជ័យ។

អង្គការវីនរ៉ក់អន្តរជាតិសូមថ្លែងអំណរគុណ ចំពោះក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលអង្គការសង្គមស៊ីវិល និង លោក លោកស្រីទាំងអស់ដែលបានចំណាយពេលវេលាដ៏មមាញឹក ក្នុងការចូលរួមផ្តល់បទសម្ភាសន៍ និងពត៌មានដើម្បីឆ្លើយតបនឹងសំណួរជាច្រើន។ការចូលរួមចំណែកនិងការណែនាំរបស់លោកលោកស្រីបានជួយអោយក្រុមសិក្សាស្រាវជ្រាវស្វែងយល់ពីស្ថានភាពបច្ចុប្បន្នរបស់ជនរងគ្រោះដោយអំពើជួញដូរ និងបានជួយដល់ការបង្កើតកម្មវិធីជាអាទិភាពផ្សេងៗ។ជាពិសេសអង្គការវីនរ៉ក់អន្តរជាតិសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ដែលបានផ្តល់មូលនិធិ និងគាំទ្រដល់ដំណើរការ នៃការសិក្សាស្រាវជ្រាវនេះ។

សូមកោតសរសើរដ៏ស្មោះស្មគ្រ័ចំពោះក្រុមសិក្សាស្រាវជ្រាវ ដែលដឹកនាំដោយទីប្រឹក្សាអន្តរជាតិ លោក Daniel Lindgrenមកពីក្រុមហ៊ុន Rapid Asiaនិង ក្រុមប្រមូលទិន្នន័យដែលដឹកនាំដោយ លោក ផ្លុង វុទ្ធី មកពីក្រុមហ៊ុន BMRS Asia (Cambodia) ។

ជាទីបញ្ចប់ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការរួមចំណែករបស់លោក លោកស្រី កុមារានិងកុមារីដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សជនដែលបានចំណាកស្រុកនិងជាក្រុមជនងាយរងគ្រោះ ដែលបានចែករំលែកពីបទពិសោធន៍ក្នុងការទទួលបានសេវាកម្មផ្សេងៗ ហើយបានជួយពួកយើងក្នុងការកំណត់ជាអនុសាសន៍ផ្សេងៗក្នុងរបាយការណ៍នេះ។

# សេចក្តីសង្ខេបនិងអនុសាសន៍

ក្រុមហ៊ុន Rapid Asia បានបង្កើតម៉ូដែលសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃកម្មវិធី (ពិន្ទុKAP)។ ក្រៅពីការប្រើប្រាស់ទូលំទូលាយក្នុងការសិក្សាពីអំពើជួញដូរមនុស្ស ពិន្ទុKAPត្រូវបានប្រើប្រាស់ក្នុងប្រធានបទពាក់ព័ន្ធមួយចំនួនផ្សេងទៀតរួមមាន ការចំណាកស្រុកសុខភាព ការអប់រំ ការអភិរក្សសត្វព្រៃ និងជំនួយគ្រោះមហន្តរាយ។ ពិន្ទុ KAP ត្រូវបានបង្កើតឡើងដើម្បីអោយបណ្តាអង្គការ និងម្ចាស់ជំនួយអាចបង្កើតនិយាមនិងវាយតម្លៃប្រកបដោយឯករាជ្យនូវឥទ្ធិពលកម្មវិធីទៅតាមពេលវេលានិងតាមតំបន់ឬប្រទេសផ្សេងៗ។ពិន្ទុKAPត្រូវបានធ្វើសុពលកម្មផ្ទៃក្នុងនិងបានបង្ហាញអោយឃើញថាជាកត្តាវាស់វែងដ៏ល្អប្រសើរសម្រាប់ការផ្លាស់ប្តូរឥរិយាបថ (សូមមើលផ្នែក"ក្របខ័ណ្ឌនៃការវាយតម្លៃជាលក្ខណៈចក្ខុវិស័យ")។

ក្របខ័ណ្ឌតែងតែកែតម្រូវទៅតាមកម្មវិធីនីមួយៗ។ ផ្អែកលើការវាយតម្លៃជាច្រើនកាលពីមុនលើអំពើជួញដូរមនុស្សក៏ដូចជាធាតុចូលពីអ្នកជំនាញសិទ្ធិមនុស្ស សំនួរគន្លឹះមួយចំនួនត្រូវបានរៀបចំសម្រាប់ក្របខ័ណ្ឌពិន្ទុ KAP ។ សំនួរនីមួយៗបានលើកឡើងពីចំណេះដឹងជាក់លាក់ បញ្ហាផ្លាស់ប្តូរឥរិយាបថឬអាកប្បកិរិយាដែលត្រូវចំគោលដៅនៃកម្មវិធីបង្ការ និងទប់ស្កាត់កំពុងតែព្យាយាមដើម្បីសម្រេចបាន។ ការផ្លាស់ប្តូរឥរិយាបថដោយមិនមានផ្នត់គំនិតត្រឹមត្រូវអាចស្ថិតនៅបានរយៈពេលខ្លីនិងមិនមានលទ្ធផលចុងក្រោយប្រកបដោយចីរភាពឡើយ។ ពិន្ទុ AP ផ្អែកលើសំអាងដែលថា ការផ្លាស់ប្តូរអាកប្បកិរិយាត្រូវទ្រទ្រង់ដោយចំណេះដឹងក៏ដូចជាឥរិយាបថគាំទ្រ។ ធាតុសំខាន់ចំនួនបីនៃក្របខ័ណ្ឌពិន្ទុKAPត្រូវបានប្រើប្រាស់នៅពេលវាយតម្លៃក្រុមងាយរង-គ្រោះជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរង-គ្រោះ ដូចជា សន្ទស្សន៍KAP បំណែងចែកហានិភ័យ និងជំនឿស៊ុប (Super Belief)។

សន្ទស្សន៍ KAP គឺជាសូចនាករដែលបានរួមបញ្ចូលចំណេះដឹងការវាស់វែងឥរិយាបថ និងអាកប្ប-កិរិយា ដើម្បីបង្កើតជាសូចនាករតួលេខមួយ។ សន្ទស្សន៍ KAP ជួយក្នុងការវាយតម្លៃដំបូង និងការប្រៀបធៀបរវាងអនុក្រុម។បំណែងចែកហានិភ័យបែងចែកអ្នកទទួលផលប្រយោជន៍ទៅជាផ្នែកទាប មធ្យម និងខ្ពស់ដោយផ្អែកលើដំណាក់កាលអភិវឌ្ឍន៍នៃផ្នត់គំនិតរបស់អ្នកទទួលផលប្រយោជន៍ ។ បើសមា-មាត្រក្រុមហានិភ័យកាន់តែខ្ពស់ នោះតម្រូវការធ្វើអន្តរាគមន៍ក៏កាន់តែខ្ពស់ដែរ ។ ជំនឿស៊ុបពិនិត្យលើឥរិយាបថ និងរបៀបភ្ជាប់សារប្រាស្រ័យទាក់ទងទៅកាន់បទដ្ឋានសង្គមនិងគុណតម្លៃផ្ទាល់ខ្លួន។

## កត្តាភាពងាយរងគ្រោះ

គោលបំណងចម្បងទីមួយនៃការសិក្សានេះគឺមើលទៅលើកត្តាភាពងាយរងគ្រោះនិងកំណត់ថាតើអ្នកដលៃត្រូវបានជួញដូរទាំងនាះអាចចងក្រងព័ត៌មានបានតាមរបៀបណាមួយមិនថាលីផ្ទនកែបម្រៃ

បម្រួលប្រជាសាស្ត្រឬស្ថានភាពសេដ្ឋកិច្ចឡើយ។ ទីពីរបណ្តុំចំណេះដឹងឥរិយាបថអាកប្បកិរិយាប្រជា-សាស្ត្រនិងកត្តាផ្សេងទៀតអាចរួមចំណែកធ្វើអោយចំណាកស្រុកមានសុវត្ថិភាព។

បម្រែបម្រួលព័ត៌មានប្រជាសាស្ត្រនិងសេដ្ឋកិច្ចផ្សេងគ្នាមួយចំនួនត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបក្រុមងាយរងគ្រោះជនចំណាកស្រុកដែលត្រឡប់មកវិញ និងអតីតជនរងគ្រោះ ។ ជាទូទៅអតីតជនរងគ្រោះជាមធ្យមមានវ័យក្មេងមានកម្រិតវប្បធម៌និងស្ថានភាពសង្គមសេដ្ឋកិច្ចទាប។ ក្នុងចំណោមចំណុចទាំងនេះកម្រិតវប្បធម៌ត្រូវបានរកឃើញថាជាកត្តាភាពងាយរងគ្រោះដ៏ចម្បងតែមួយគត់។គួរកត់សម្គាល់ថាអតីតជនរងគ្រោះ ៨៣%ដែលឆ្លងកាត់ការសម្ភាសន៍ សិក្សាបានត្រឹមកម្រិតសាលាបឋមសិក្សាប៉ុណ្ណោះ។

បើគិតលើបញ្ហាសេដ្ឋកិច្ចអតីតជនរងគ្រោះមានស្ថានភាពក្រីក្រក្នុងទិដ្ឋភាពជាច្រើន ។ ស្ទើរពាក់កណ្តាល (៤៧%)នៃអតីតជនរងគ្រោះដែលឆ្លងកាត់ការសម្ភាសន៍មិនមានលទ្ធភាពទិញអាហារធៀបនឹង២៨ភាគរយនៃក្រុមដទៃនិងមានបញ្ហាសន្តិសុខស្បៀង។ថ្វីត្បិតតែពីរភាគបីមានដីបង្កបង្កើនផលពួកគាត់ត្រូវទិញអង្ករជាមធ្យមប្រាំពីរខែក្នុងមួយឆ្នាំធៀបនឹងចំនួនត្រឹមតែបីខែសម្រាប់ក្រុមងាយរងគ្រោះ។

នៅពេលដែលកម្រិតវប្បធម៌និងសន្តិសុខស្បៀងអាហារជាកត្តាងាយរងគ្រោះលេចធ្លោចម្បងទាំងពីរគេរកឃើញថាអតីតជនរងគ្រោះបានឆ្លងកាត់កត្តាបង្កភាពងាយរងគ្រោះនៅក្នុងទ្រង់ទ្រាយធំជាងនេះ។ កត្តាបង្កភាពងាយរងគ្រោះនៅទីនេះមានន័យថាជាហេតុការណ៍ដែលអាចកើតឡើងភ្លាមៗ ហើយមិនអាចគ្រប់គ្រងបានដូចជាគ្រោះធម្មជាតិនិងជំងឺ។ អតីតជនរងគ្រោះជាមធ្យមឆ្លងកាត់កត្តាបង្កភាពងាយរងគ្រោះស្ទើរតែបីដងកន្លះនៅក្នុងរយៈពេល ១២ខែធៀបនឹងចំនួនតែពីរដងចំពោះជនងាយរងគ្រោះនិងជនចំណាកស្រុកដែលវិលត្រឡប់។ ជំងឺបំណុលគ្រោះធម្មជាតិការបោះបង់ចោលការសិក្សានិងការបែកបាក់គ្រួសារគឺជាគន្លឹះបង្កដែលលេចធ្លោ។

សេចក្តីសន្និដ្ឋានដែលយើងអាចទាញបានពីចំណុចនេះគឺអាចមានការពិបាកក្នុងការបែងចែកទីផ្សារទៅតាមអ្នកដែលងាយរងគ្រោះ និងអ្នកមិនសូវងាយរងគ្រោះដោយពិនិត្យលើស្ថានភាពប្រជាសាស្ត្រនិងសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពងាយរងគ្រោះងាយនឹងកើតឡើងណាស់ហើយតែងតែកើតឡើងដោយសារហេតុការណ៍ភ្លាមៗ (គន្លឹះបង្កភាពងាយរងគ្រោះ) ដែលជំរុញអោយបុគ្គលធ្លាក់ក្នុងស្ថានភាពដែលពួកគេអស់សង្ឃឹម។ជាទូទៅវាគឺជាហេតុការណ៍ចម្រុះគ្នាជាជាងហេតុការណ៍តែមួយហើយស្ថានភាពជាក់លាក់អាចខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

ចំណុចនេះរំលេចឡើងនូវតម្រូវការលើការអប់រំបង្ការដោយមានការសង្កត់ធ្ងន់ជាក់លាក់លើចំណាកស្រុកដោយសុវត្ថិភាព។ នៅពេលដែលមនុស្សក្លាយជាអស់សង្ឃឹម គេអាចធ្វើការសម្រេចចិត្តដោយតក់ក្រហល់ដូច្នេះហើយទើបការយល់ដឹងពីហានិភ័យមានសារៈសំខាន់ប៉ុន្តែសំខាន់ជាងនេះទៅទៀតនោះគឺជនចំណាកស្រុកក៏ចាំបាច់ត្រូវដឹងពីកន្លែងដែលពួកគេអាចស្វែងរកជំនួយ និងវិធានការត្រូវអនុវត្តដើម្បីធានាថាពួកគេមិនប្រឈមមុខនឹងហានិភ័យ។

ខណៈដែលការយល់ដឹងពីអំពើជួញដូរមនុស្សមានកម្រិតខ្ពស់ (៨៥-១០០%)ប្រភពនៃការយល់ដឹងខុសគ្នាទៅតាមផ្នែកនីមួយៗ។មួយភាគបីនៃអតីតជនរងគ្រោះមិនអាចទទួលព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយហើយពីរភាគបីមិនមានទូរស័ព្ទចល័ត។ ហេតុនេះពួកគេកាន់តែពឹងផ្អែកលើទំនាក់ទំនងពីមាត់

មួយទៅមាត់មួយក្នុងការទទួលបានព័ត៌មានពីអំពើជួញដូរមនុស្ស។ ដូច្នេះមិនមានការភ្ញាក់ផ្អើលទេដែលថាការទទួលបានអន្តរាគមន៍ពីអំពើជួញដូរមនុស្ស ពីអតីតកាលគឺទាបជាងសម្រាប់អតីតជនរងគ្រោះ (២០%) ធៀបនឹងក្រុមជនងាយរងគ្រោះ (២៧%)និងជនចំណាកស្រុក (២៥%)។ ភាពខុសគ្នាដែលគួរអោយចាប់អារម្មណ៍មួយទៀតនោះគឺប្រហែលមួយភាគបីនៃក្នុងក្រុមនីមួយៗ ស្គាល់សាច់ញាតិ ឬមិត្តភក្តិដែលបានធ្វើចំណាកស្រុកប៉ុន្តែស្ទើរតែគ្រប់ករណីនៃចំណាកស្រុកមិនមានសុវត្ថិភាព គឺជាមិត្តភក្តិនិងសាច់ញាតិរបស់អតីតជនរងគ្រោះ។

ជាផ្នែកនៃការវាយតម្លៃភាពងាយរងគ្រោះម៉ូដែលពិន្ទុ KAP ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងភាពងាយរងគ្រោះដោយផ្អែកលើការយល់ដឹងរបស់អ្នកទទួលផលពីអំពើជួញដូរមនុស្ស ឥរិយាបថរបស់ពួកគេពាក់ព័ន្ធនឹងបញ្ហានេះព្រមទាំងអាកប្បកិរិយាចូលរួម ឬគោលបំណងជាឥរិយាបថដែលអាចជាករណីនេះ ។ ក្របខ័ណ្ឌនេះមានប្រយោជន៍ដោយសារវាជួយក្នុងការវាយតម្លៃភាពងាយរងគ្រោះពីទស្សនៈខុសៗគ្នាដោយមិនគិតអំពីចំណែកអ្នកទទួលផលព័ត៌មានប្រជាសាស្ត្រឬស្ថានភាពសេដ្ឋកិច្ច។

សន្ទស្សន៍ KAP ត្រូវបានរកឃើញថាស្រដៀងគ្នាខ្លាំងក្នុងផ្នែកទាំងបីដោយមានចំនួន ១០២ សម្រាប់ក្រុមជនងាយរងគ្រោះ ១០៩ សម្រាប់ជនចំណាកស្រុកដែលវិលត្រលប់ និង ១០៦ សម្រាប់អតីតជនរងគ្រោះ។ ចំណុចនេះបង្ហាញថាមនុស្សជាច្រើនមិនបានធ្វើចំណាកស្រុកដោយសុវត្ថិភាពទេហើយនៅតែងអាចជួបនូវហានិភ័យ។ លើសពីនេះអតីតជនរងគ្រោះជាច្រើនមិនបានរៀនសូត្រពីបទពិសោធន៍របស់ខ្លួនទេហើយនៅតែអាចប្រឈមនឹងហានិភ័យ។ ជាទូទៅបំណែងចែកហានិភ័យបង្ហាញថា ប្រមាណជា៦០ភាគរយនៅក្នុងក្រុមនីមួយៗអាចចាត់ទុកថាមានហានិភ័យខ្ពស់ និងមានន័យថាអន្តរាគមន៍បង្ការនាពេលអនាគតគួរកំណត់គោលដៅសម្រាប់ផ្នែកទាំងបី។

នៅពេលពិនិត្យលើការយល់ដឹងអំពីបញ្ហាជួញដូរមនុស្ស ការយល់ដឹងគឺស្រដៀងគ្នានៅទូទាំងផ្នែកទាំងបីហើយគម្លាតសំខាន់ចំនួនបីត្រូវបានកំណត់។ទីមួយ ការយល់ដឹងនៅមានកម្រិតអំពីនិយមន័យនៃអំពើជួញដូរមនុស្សហើយមនុស្សជាច្រើនយល់ច្រឡំពាក្យនេះជាមួយនឹងមនុស្សដែលប្រព្រឹត្តអំពើជួញដូរឬន័យបញ្ច្រាស់មកវិញ។ ទីពីរ មនុស្សជាច្រើនមិនបានដឹងថាស្ត្រី បុរសនិងកុមារប្រឈមនឹងហានិភ័យដោយមនុស្សភាគច្រើនជឿថាមានតែស្ត្រីប៉ុណ្ណោះដែលប្រឈមនឹងហានិភ័យនេះ ។ ផ្សាភ្ជាប់នឹងបញ្ហានេះគឺការមិនសូវយល់ដឹងអំពីទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចរួមមាន កេងប្រវ័ញ្ចផ្លូវភេទពលកម្មដោយបង្ខំ និងសេវភាពក្នុងស្រុកដោយបង្ខំ។ នេះគឺជាសូចនាករដ៏រឹងមាំដែលអ្នកទទួលផលមិនមានភាពស៊ាំនឹងទស្សនាទាននៃអំពើជួញដូរមនុស្សហើយមានន័យថាពួកគេមិនស្គាល់អំពីស្ថានភាពដែលមាន ហានិភ័យខ្លាំងក្លាទោះបីជាពួកគេដឹងថាជនរងគ្រោះត្រូវបានគេបញ្ឆោត និងដឹងថាអំពើជួញដូរកើតឡើងក្នុងប្រទេសកម្ពុជាក៏ដោយ។

ព័ត៌មានឥរិយាបថក៏ស្រដៀងគ្នាផងដែរសម្រាប់ផ្នែកទាំងបី ទាំងចំពោះឥរិយាបថវិជ្ជមាននិងអវិជ្ជមាន។ ប៉ុន្តែជនចំណាកស្រុកដែលវិលត្រឡប់អាចមានឥរិយាបថវិជ្ជមានជាងបន្តិច។អតីតជនរងគ្រោះត្រូវរកឃើញថាមានចរិតបដិសេធទៅនឹងបរិបទធំធេងហើយឥរិយាបថនេះអាចជះឥទ្ធិពលមកពីបទពិសោធរបស់ពួកគេ។ ពួកគេអាចបង្ហាញភាពព្រងើយកន្តើយនិងភាពមិនយកចិត្តទុកដាក់ច្រើន ។ នៅក្នុងក្រុមទាំងបីឥរិយាបថអវិជ្ជមានដែលខ្លាំងក្លាជាងគេគឺការរើសអើង។ គំនិតនេះគឺថាមនុស្សដែលត្រូវ

បានជួញដូរអាចមានជីវភាពកាន់តែប្រសើរជាពិសេសប្រសិនបើគេមិនទាន់មានការងារធ្វើ ។ គួរអោយចាប់អារម្មណ៍ដែលថាអ្នករួចខ្លួនយល់ស្របនឹងគំនិតនេះទោះបីពួកគេធ្លាប់មានបទពិសោធន៍ក៏ដោយ។ នៅក្នុងករណីខ្លះនេះអាចជាទម្រង់នៃការបដិសេធដើម្បីបង្ហាញហេតុផលពីទង្វើរបស់ពួកគេ។

ឥរិយាបថបង្ការត្រូវបានវាស់វែងដោយពិនិត្យលើគោលបំណងជាឥរិយាបថទាក់ទងនឹងចំណាកស្រុកដោយសុវត្ថិភាព។ ជាទូទៅមានលទ្ធផលទាបលើកលែងតែចេតនារាយការណ៍អំពីបទឧក្រិដ្ឋ។ការស្វែងរកដំបូន្មានឯករាជ្យអំពីការងារក្រៅប្រទេស ការមិនយកចិត្តទុកដាក់ចំពោះភ្នាក់ងារដែលផ្តល់ព័ត៌មានមិនត្រឹមត្រូវការអប់រំមិត្តភក្តិអំពីបញ្ហាជួញដូរមនុស្ស និងការដឹងពីទីកន្លែងស្វែងរកព័ត៌មានពីអំពើជួញដូរមនុស្សសុទ្ធតែមានការអនុវត្តតាមទាបជាង (ចន្លោះពី ១០%-៤០%)។ ដោយពិចារណាលើចំណុចនេះ និងការពិតដែលថាមនុស្សជាច្រើនមិនដឹងថាតើត្រូវការក្រដាសស្នាមអ្វីខ្លះដើម្បីធ្វើការក្នុងប្រទេសដទៃគឺជាភស្តុតាងច្បាស់លាស់ចំពោះកម្រិតងាយរងគ្រោះខ្ពស់។

ការវិភាគគ្រប់ជ្រុងជ្រោយបានធ្វើឡើងដើម្បីកំណត់ចំណែកងាយរងគ្រោះចម្បងហើយទំនាក់ទំនងខាងក្រោមត្រូវបានរកឃើញ៖

- ភាពងាយរងគ្រោះថយចុះនៅពេលមានកម្រិតវប្បធម៌ខ្ពស់ ។ នេះបញ្ជាក់ពីអ្វីដែលបានអះអាងកាលពីមុនថាកម្រិតវប្បធម៌គឺជាឧបករណ៍បង្ការចម្បង ហើយកម្មវិធីបង្ការគួរពិចារណាអំពីការធ្វើកិច្ចសហការជាមួយសាលារៀន និងកំណត់គោលដៅសិស្សនៅសាលាបឋមសិក្សា។
- ជាទូទៅស្ត្រីមានភាពងាយរងគ្រោះជាងបុរសបន្តិចប៉ុន្តែមានភាពខុសគ្នាតិចតួចប៉ុណ្ណោះ។
- ភាពងាយរងគ្រោះថយចុះបន្តិចសម្រាប់អ្នកដែលមានជីវភាពគ្រាន់បើដូចជាមានដីឬមានស្ថានភាពសង្គមសេដ្ឋកិច្ចខ្ពស់ជាង ។ ជាថ្មីម្តងទៀតភាពខុសគ្នាគឺតិចតួចប៉ុន្តែបង្ហាញពីតម្រូវការចាំបាច់លើការអន្តរាគមន៍ប្រភេទបង្ការ។
- មានភស្តុតាងច្បាស់ថាអន្តរាគមន៍ពីមុន មានឥទ្ធិពលមួយចំនួនដែលជាទូទៅធ្វើអោយកើនសន្ទស្សន៍ KAP រហូតដល់១១៥-១១៦។ ទោះជាយ៉ាងណាក៏ដោយការសម្រេចបានជាទូទៅមានកម្រិតទាប ហើយក្រុមហានិភ័យខ្ពស់នៅតែមានទំហំធំ។

## គន្លឹះបង្កហានិភ័យ

ដើម្បីកំណត់កត្តាបង្កហានិភ័យដែលមានសក្តានុពលខ្សែចង្វាក់ផ្គត់ផ្គង់សម្រាប់អំពើជួញដូរមនុស្សត្រូវចែកចេញជាប្រាំជំហានសំខាន់ចាប់តាំងពីពេលដែលមនុស្សម្នាក់បានដឹងពីឱកាសការងាររហូតទៅដល់ចំណុចដែលពួកគេបានទៅដល់ចំណុចគោលដៅ ។ ជំហានទាំងប្រាំត្រូវប្រើប្រាស់ជាមគ្គុទេសន៍ដើម្បីជួយផ្តោតការពិភាក្សាទៅលើកកត្តាបង្កហានិភ័យដែលមានសក្តានុពល និងវិសាលភាពដែលកត្តាបង្កអាចអនុវត្តបានក្នុងករណីនីមួយៗ ។ ខ្សែចង្វាក់ផ្គត់ផ្គង់ត្រូវបានវាស់វែងសម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះដូច្នេះអាចធ្វើការប្រៀបធៀបដើម្បីកំណត់កត្តាបង្កហានិភ័យដែលជាកត្តាជំរុញសក្តានុពលធ្វើអោយជនចំណាកស្រុកក្លាយជាជនដែលត្រូវបានគេជួញដូរ។

នៅជំហានទីមួយ (ដឹងពីឱកាសការងារ) ច្បាស់ណាស់ដែលថាអតីតជនរងគ្រោះបានដឹងអំពីឱកាសការងារពីមេខ្យល់ឬភ្នាក់ងារនៅក្នុងទ្រង់ទ្រាយធំ ។ ជនចំណាកស្រុកជាងពាក់កណ្តាលបានដឹងអំពីឱកាសការងារពីមេខ្យល់ឬភ្នាក់ងារធៀបនឹង ៣០ភាគរយសម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់។

នៅជំហានទីពីរ (ស្រាវជ្រាវព័ត៌មាន) ជនចំណាកស្រុកនឹងជួបជាមួយភ្នាក់ងារឬនិយោជក់ហើយចំណុចផ្តោតនៅទីនេះគឺជាប្រភេទព័ត៌មានដែលផ្តល់អោយ ឬស្វែងរកយ៉ាងស្វះស្វែងដោយជនចំណាកស្រុក។ មេខ្យល់ដែលប្រើប្រាស់ដោយអតីតជនរងគ្រោះត្រូវបានរកឃើញថាកម្រនឹងបញ្ចេញឈ្មោះភ្នាក់ងារដែលពួកគេតំណាងអោយឈ្មោះភ្នាក់ងារត្រូវបានបង្ហាញតែ១៧ភាគរយនៃករណីធៀបនឹង៤៦ភាគរយសម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់ ។ ជាធម្មតាភ្នាក់ងារមិនផ្តល់ប្រាក់ឬអំណោយនោះទេ ប៉ុន្តែនៅក្នុងករណីអតីតជនរងគ្រោះទម្រង់ផ្តល់រង្វាន់លើកទឹកចិត្តមួយចំនួនមានប្រមាណ២០ភាគរយនៃករណី។ អតីតជនរងគ្រោះក៏កម្រនឹងស្វែងរកដំបូន្មានឯករាជ្យអំពីការងារ (២៣%ជាមួយនឹង៦០% សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់)។ លើសពីនេះនៅពេលដែលអតីតជនរងគ្រោះចំនួន៨៣% បានសួរសំនួរខ្លះអំពីការងារជាមធ្យមពួកគេគ្រាន់តែសួរសំនួរគន្លឹះមួយធៀបនឹងសំនួរគន្លឹះពីរដែលសួរដោយជនចំណាកស្រុកដែលវិលត្រឡប់ ។ មិនមានភាពខុសគ្នាខ្លាំងប៉ុន្មាននោះទេប៉ុន្តែអ្នកជួញដូរជាច្រើននឹងគេចវេសនៅពេលដែលគេជួបនឹងសំនួរច្រើនហួសហេតុ ដូច្នេះហើយរាល់សំនួរបន្ថែមគឺមានប្រយោជន៍។

នៅក្នុងអំឡុងជំហានទីបី (សម្រេចចិត្តទៅ) អតីតជនរងគ្រោះជាងពាក់កណ្តាលអាស្រ័យលើមេខ្យល់ក្នុងការផ្តល់កម្រៃធ្វើដំណើរឬត្រូវការខ្ចីប្រាក់ (ធៀបនឹង២៦%នៃជនចំណាកស្រុកដែលវិលត្រឡប់)។ ដូច្នេះថ្លៃចំណាយធ្វើដំណើររបស់ពួកគេ ជាមធ្យមមានចំនួនទាបជាងធៀបនឹងជនចំណាកស្រុកដែលវិលត្រឡប់ប៉ុន្តែ ៥៨% ជំពាក់បំណុលមេខ្យល់ ។ នៅក្នុងចំណោមជនចំណាកស្រុកដែលវិលត្រឡប់មានតែ ២១% ប៉ុណ្ណោះដែលជាប់បំណុលសម្រាប់ចំណាយធ្វើដំណើរ។

នៅជំហានទីបួន (ការរៀបចំការធ្វើដំណើរ) កត្តាបង្កហានិភ័យចម្បងគឺអតីតជនរងគ្រោះចំនួន ៣០% មិនបានយកលុយខ្លួនឯងមកទេធៀបនឹង ១២% សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់។ អតីតជនរងគ្រោះមិនទំនងជាចុះកិច្ចសន្យាទេ (១០%ទល់នឹង២១%)ហើយដឹងពីខ្សែទូរស័ព្ទបន្ទាន់ (៤០%ទល់នឹង៥៥%)។ កាន់តែសំខាន់ជាងនេះទៀតនោះគឺប្រហែលជាមានអតីតជនរងគ្រោះតែ ២២% ប៉ុណ្ណោះដែលរៀបចំការធ្វើដំណើរដោយខ្លួនគេផ្ទាល់ធៀបនឹង ៦៨% នៃជនចំណាកស្រុកដែលវិលត្រឡប់។

មិនមានអ្វីចម្លែកទេនៅក្នុងជំហានទីប្រាំ (មកដល់ចំណុចគោលដៅ) អតីតជនរងគ្រោះទាំងអស់ជួបប្រទះនឹងស្ថានភាពការងារដែលអាក្រក់ (៧២%ទល់នឹង៦%)ឬអាក្រក់ជាង (២៨%ទល់នឹង៦%)ការរំពឹងទុកបន្តិច។ អតីតជនរងគ្រោះស្ទើរតែទាំងអស់ក៏ជួបប្រទះផងដែរ នូវទម្រង់នៃអំពើហិង្សាមួយឬច្រើនរួមមានការគំរាមគំហែង (៦៣%)ទាសភាពបំណុល (៤៨%)និងត្រូវបានគេតាមចាប់ (៧៧%)។

នៅពេលរំពឹងថានឹងទទួលបានលទ្ធផល លទ្ធផលទាំងនោះបង្ហាញយ៉ាងច្បាស់ថាអតីតជនរងគ្រោះមិនត្រូវបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើចំណាកស្រុកដោយសុវត្ថិភាពនៅកន្លែងដំបូងទាំងផ្នត់គំនិតនិងកត្តាងាយរងគ្រោះ។ ប៉ុន្តែសំខាន់ជាងនេះទៅទៀតនោះគឺគ្រាន់តែមនុស្សម្នាក់បានធ្វើចំណាកស្រុកដោយសុវត្ថិភាពមិនមែនមានន័យថាពួកគេអាចបង្ការបានពីអំពើជួញដូរមនុស្សនោះទេ។កត្តាបង្កហានិ-

ភ័យដើរតួជាចម្បងជាងអ្វីដែលបានរំពឹងទុក។ ការបង្កើតការរំពឹងទុកនេះគឺជាគន្លឹះឆ្ពោះទៅចំណាកស្រុកដោយសុវត្ថិភាពហើយអាចមានភាពសាមញ្ញដូចជាការសួរសំនួរបន្ថែមមួយចំនួនទៅកាន់មេខ្យល់ស្វែងរកដំបូន្មានឯករាជ្យអំពីការងារឬប្រាជកថាផ្តល់ច្បាប់ចម្លងលិខិតឆ្លងដែនមុនពេលធ្វើដំណើរ។

## ការផ្សារភ្ជាប់

ដ្យាក្រាមខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងកត្តាងាយរងគ្រោះកត្តាបង្កភាពងាយរងគ្រោះនិងកត្តាបង្កហានិភ័យ។ ចំណាកស្រុកដោយសុវត្ថិភាពពិតជាអាស្រ័យលើការអប់រំតាមរយៈអន្តរាគមន៍បង្ការដែលមានប្រសិទ្ធភាព។ កិច្ចសហការរវាងការអប់រំនិងកម្មវិធីសន្តិសុខស្បៀងគឺជាចំណុចចាប់ផ្តើមដ៏ល្អប្រសើរដោយសារការអប់រំនិងសន្តិសុខស្បៀងនឹងជួយបន្ធូរបន្ថយកត្តាបង្កភាពងាយរងគ្រោះ ។ អន្តរាគមន៍បង្ការនឹងជួយកាត់បន្ថយឥទ្ធិពលនៃកត្តាបង្កហានិភ័យ ។ ជាមួយគ្នាការអប់រំនិងសន្តិសុខស្បៀង អាចជួយទាញនិងទប់ជនចំណាកស្រុកអោយនៅក្នុងតំបន់ចំណាកស្រុកដែលមានសុវត្ថិភាព។

## សារនិងយុទ្ធសាស្រ្តទប់ស្កាត់



# សារនិងយុទ្ធសាស្ត្រទប់ស្កាត់

| កត្តាភាពងាយរងគ្រោះ | សារទប់ស្កាត់ |
|---|---|
| ចំណេះដឹង | • អំពើជួញដូរមនុស្សមិនមែនជាការរត់ពន្ធមនុស្សនោះទេនេះគឺជាការយល់ខុស<br>• បុរសស្ត្រីនិងកុមារគឺប្រឈមនឹងហានិភ័យ<br>• ការកេងប្រវ័ញ្ចកើតមាននៅក្នុងវិស័យជាច្រើនមិនមែនតែនៅក្នុងវិស័យផ្លូវភេទប៉ុណ្ណោះទេ |
| អាកប្បកិរិយា | • ភាពប្រងើយកន្តើយការបដិសេធនិងការរើសអើងគឺជាអាកប្បកិរិយាអវិជ្ជមានខ្លាំងក្លាដែលរារាំងដល់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។សារត្រូវតែសង្កត់ធ្ងន់បញ្ហាទាំងនេះពីទស្សនៈប្រកបដោយមនោសញ្ចេតនា។ |
| ឥរិយាបថ | • តែងតែស្វែងរកដំបូន្មានឯករាជ្យអំពីការងារ<br>• ប្រយ័ត្នប្រយែងចំពោះភ្នាក់ងារនិងមេខ្យល់តែងតែពិនិត្យមើលព័ត៌មាន<br>• អប់រំមិត្តភក្តិអំពីបញ្ហាជួញដូរមនុស្ស<br>• ស្គាល់កន្លែងស្វែងរកព័ត៌មានដែលគួរអោយទុកចិត្ត |

| ដំណាក់កាលខ្សែចង្វាក់ផ្គត់ផ្គង់ | យុទ្ធសាស្ត្រទប់ស្កាត់ | |
|---|---|---|
| ដឹងពីឱកាសការងារ | • ប្រយ័ត្នប្រយែងចំពោះមេខ្យល់និងភ្នាក់ងារ | សំខាន់បំផុត |
| ទំនាក់ទំនងដំបូងជាមួយនឹងមេខ្យល់ | • ជានិច្ចកាលត្រូវសួរឈ្មោះអង្គភាពពីភ្នាក់ងារ<br>• ស្វែងរកដំបូន្មានឯករាជ្យសួរសំនួរបើអំពីការងារ៖ ឧ.ប្រាក់ខែលក្ខខណ្ឌការងារចំនួនម៉ោងធ្វើការ។ល។ | |
| សម្រេចចិត្តទៅ | • សួររកកិច្ចសន្យាឬកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ<br>• ជៀសវាងការខ្ចីប្រាក់ពីមេខ្យល់ដើម្បីយកមកធ្វើជាសោហ៊ុយធ្វើដំណើរ | |
| រៀបចំធ្វើដំណើរ | • រៀបចំការធ្វើដំណើរដោយខ្លួនឯងបើអាចធ្វើបាន<br>• តែងតែយកប្រាក់ទៅជាមួយទោះបីជាតិចតួចក៏ដោយ<br>• កត់ត្រាទុកលេខទូរស័ព្ទបន្ទាន់ហើយយកទូរស័ព្ទចល័តទៅជាមួយបើអាចធ្វើបាន<br>• ទុកច្បាប់ចម្លងលិខិតឆ្លងដែន<br>• កុំប្រគល់លិខិតឆ្លងដែនទៅអ្នកណាអោយសោះ | |

# សាវតារនិងវិធីសាស្រ្ត

## ការសិក្សាឯករាជ្យចំនួនពីរការវាយតម្លៃភាពងាយរងគ្រោះជាមួយនឹងសហគមន៍ទូទៅ និងសិក្សាខ្សែចង្វាក់ផ្គត់ផ្គង់ជាមួយនឹងជនចំណាកស្រុកនិងអតីតជនរងគ្រោះ

## សាវតារ

អំពើជួញដូរគឺជាបញ្ហាដែលកំពុងកើនឡើងទូទាំងពិភពលោក ហើយជនរងគ្រោះច្រើនជាងម្នាក់ក្នុងចំណោមជនរងគ្រោះពីរនាក់មកពីប្រទេសកំពុងអភិវឌ្ឍន៍នៅទ្វីបអាស៊ីនិងតំបន់ប៉ាស៊ីហ្វិក។កម្ពុជាគឺជាប្រទេសដែលពាក់ព័ន្ធនឹងការផ្ទេរផ្តល់ជម្រកខុសច្បាប់និងទទួលជនដែលត្រូវគេជួញដូរ ។ ភាពក្រីក្រនិកម្មភាពមូលដ្ឋានបាត់បង់ដីធ្លី និងបំណងប្រាថ្នាសម្រាប់ជីវិតដែលល្អប្រសើរសុទ្ធសឹងតែជាកត្តាជំរុញអោយប្រទេសកម្ពុជាមានអត្រាចំណាកស្រុកក្នុងប្រទេសនិងឆ្លងប្រទេសខ្ពស់ ។ ខេត្តព្រៃវែងនិងខេត្តស្វាយរៀងគឺប្រភពនិងចំណុចឆ្លងកាត់ទៅកាន់ប្រទេសវៀតណាមខណៈដែលខេត្តសៀមរាបនិងក្រុងភ្នំពេញជាប្រភពផ្គត់ផ្គង់ពលកម្មទៅប្រទេសម៉ាឡេស៊ី កូរ៉េ និង អារ៉ាប់ប៊ីសាអ៊ូឌីត។ បុរសនិងស្ត្រីជាច្រើនធ្វើចំណាកស្រុកហើយត្រូវបានជួញដូរទៅកាន់ប្រទេសដទៃដើម្បីធ្វើការជាពិសេសទៅកាន់ប្រទេសថៃវៀតណាមនិងម៉ាឡេស៊ី។ជនចំណាកស្រុកទៅកាន់ប្រទេសថៃត្រូវបានផ្តល់ប្រភពនិងឆ្លងកាត់តាមខេត្តបាត់ដំបងកោះកុងនិងបន្ទាយមានជ័យ។

ជារឿយៗអង្គការមិនមែនរដ្ឋាភិបាលបានគូសបញ្ជាក់ថាកុមារី និងស្ត្រីងាយនឹងរងគ្រោះទៅនឹងទាសភាពតាមផ្ទះជាពិសេសនៅក្នុងប្រទេសម៉ាឡេស៊ី ។ ប៉ុន្តែបុរសជាច្រើនត្រូវបានបញ្ជូនអោយទៅធ្វើការលើទូកនេសាទក្នុងប្រទេសថៃ ហើយខ្លះទៀតត្រូវបានប្រគល់បន្តឬលក់ទៅប្រទេសដទៃដូចជាប្រទេសម៉ាឡេស៊ី ឥណ្ឌា សូម៉ាលី ទីម័រ អារ៉ាប់ប៊ីសាអ៊ូឌីត និងអាហ្វ្រិកខាងត្បូង។ កុមារមួយចំនួនជាពិសេសកុមារដែលមកពីស្រុកដែលមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ត្រូវបានជួញដូរដើម្បីធ្វើជាអ្នកសុំទាន។

ចំណុចអភិវឌ្ឍសំខាន់បំផុតសម្រាប់អង្គការ Winrock គឺការទប់ស្កាត់អំពើជួញដូរមនុស្ស ។ យុទ្ធសាស្រ្តទប់ស្កាត់មានឥទ្ធិពលដោយសារ គេស្វែងរកប្រភពបញ្ហាហើយដូចដែលបានកំណត់ឃើញនៅក្នុងប្រទេសកម្ពុជាមនុស្សនៅក្នុងសហគមន៍ដែលប្រឈមនឹងហានិភ័យខ្ពស់ មានការយល់ដឹងតិចតួចពីអំពើជួញដូរមនុស្សដែលបណ្តាលអោយពួកគេមិនអាចធ្វើចំណាកស្រុកដោយសុវត្ថិភាព ។ អង្គការ Winrock ក៏មានបំណងសង្កត់ធ្ងន់ផងដែរ លើបុរសដែលត្រូវបានគេកេងប្រវ័ញ្ចដែលនៅតែមានចំនួនច្រើនហើយជាធម្មតាមិនត្រូវបានចាត់ទុកថាជាក្រុមដែលប្រឈមនឹងហានិភ័យទេ។

## ការបង្កើតការសិក្សា

របាយការណ៍នេះគ្របដណ្តប់ដំណាក់កាលបរិមាណចុងក្រោយនៃការសិក្សា។ គម្រោងទាំងមូលក៏រួមបញ្ចូលផងដែរនូវការពិនិត្យមើលឯកសារឡើងវិញនិងកិច្ចសម្ភាសន៍គុណភាពជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ។ការពិនិត្យមើលឯកសារឡើងវិញ (ដំណាក់កាលទី១)ត្រូវបានធ្វើមុនដើម្បីចង្អុលបង្ហាញគម្លាតការវាយតម្លៃសំខាន់ដែលមិនបានគ្របដណ្តប់ពេញលេញនៅក្នុងការសិក្សាពីលើកមុន។ទិដ្ឋភាពនៃអំពើជួញដូរ (ដំណាក់កាលទី២)គឺជាទម្រង់នៃការសម្ភាសន៍ស៊ីជម្រៅជាមួយនឹងភាគីពាក់ព័ន្ធសំខាន់ៗ

ដែលរួមមានៈបុគ្គលិកសង្គមកិច្ចអង្គអាជ្ញាធរមូលដ្ឋានមន្ទីរពាក់ព័ន្ធនិងប៉ូលីសអន្តោប្រវេសន៍។ព័ត៌មានដែលប្រមូលបាននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ត្រូវបានដាក់បញ្ចូលទៅក្នុងការសម្រង់មតិបរិមាណចំនួនពីរលើខ្សែចង្វាក់ផ្គត់ផ្គង់អំពើជួញដូរ (ដំណាក់កាលទី៣)និងការវាយតម្លៃភាពងាយរងគ្រោះ(ដំណាក់កាលទី៤)។ដោយមានការចូលរួមផ្តល់យោបលពីអង្គការវីនរ៉ក់(Winrock)ព័ត៌មានត្រូវបានប្រើប្រាស់ជាចម្បងដើម្បីបង្កើតកម្រងសំណួរនិងរៀបចំផែនការគំរូ។




## គោលបំណងការសិក្សាភាពងាយរងគ្រោះ

គោលបំណងរួមគឺស្វែងយល់ពីភាពងាយរងគ្រោះនិងកំណត់ពីទំហំដែលគម្លាតចំណេះដឹងឥរិយាបថមិនប្រក្រតីនិងអាកប្បកិរិយាហានិភ័យខ្លាំងក្លាពាក់ព័ន្ធនឹងភាពងាយរងគ្រោះ។ក្រុមហ៊ុន Rapid Asia បានបង្កើតក្របខ័ណ្ឌដើម្បីវាស់វែងដែលហៅថាពិន្ទុKAP។ក្របខ័ណ្ឌនេះអាចប្រើប្រាស់ដើម្បីឆ្លើយតបគោលបំណងដូចខាងក្រោម៖

- ចង្អុលបង្ហាញផ្នែកដែលងាយរងគ្រោះ និងចងក្រងព័ត៌មានទាំងនេះផ្អែកលើប្រជាសាស្ត្រឬបទពិសោធន៍ពីមុននិងកាលៈទេសៈស្ថានភាព
- បង្កើតធាតុចូលជាក់លាក់សម្រាប់បង្កើតសារដែលប្រសិទ្ធភាព
- កំណត់វិសាលភាពឥទ្ធិពលរបស់អន្តរាគមន៍ពីមុន
- វាស់វែងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទាំងប្រព័ន្ធផ្សព្វផ្សាយទូទៅនិងប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីការជ្រើសរើសច្រកទំនាក់ទំនងសម្រាប់អន្តរាគមន៍នាពេលអនាគត។
- វាស់វែងឥរិយាបថដែលទាក់ទងជាទូទៅជាមួយនឹងអំពើជួញដូរមនុស្សដែលរួមមាន៖
- **ការបដិសេធ**បញ្ហានៃអំពើជួញដូរមនុស្ស
- **បុរេនិច្ឆ័យ (ស្លាកស្នាមទុរយស)** ចំពោះអតីតជនរងគ្រោះពីអំពើជួញដូរមនុស្ស
- **ការរើសអើង**មនុស្សដែលត្រូវបានគេជួញដូរ
- **ភាពព្រងើយកន្តើយ**គិតថាមិនចាំបាច់ខ្វល់ខ្វាយពីបញ្ហានេះឡើយ
- **ភាពមិនយកចិត្តទុកដាក់**ពាក់ព័ន្ធនឹងរបៀបដែលមនុស្សធ្លាក់ខ្លួនទៅអោយគេជួញដូរ

## គោលបំណងសិក្សាខ្សែចង្វាក់ផ្គត់ផ្គង់

នៅខណៈដែលអង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នដទៃដែលពាក់ព័ន្ធធ្វើការពាក់ព័ន្ធនឹងអំពើ

ជួញដូរមនុស្សអាចផ្តល់ព័ត៌មានខ្លីៗអំពីខ្សែចង្វាក់ផ្គត់ផ្គង់អំពើជួញដូរមនុស្សគោលបំណងគឺដើម្បីទាញយក "រឿងពិត" ផ្ទាល់ពីជនចំណាកស្រុកនិងអតីតជនរងគ្រោះ។ ការប្រៀបធៀបត្រូវធ្វើឡើងរវាងអ្នកដែលបានធ្វើចំណាកស្រុកប្រកបសុវត្ថិភាពនិងអតីតជនរងគ្រោះដើម្បីកំណត់ "កត្តាងាយរងគ្រោះ" ចម្បង និង "កត្តាបង្កហានិភ័យ"។ការប្រៀបធៀបធ្វើឡើងជាទម្រង់រចនាសម្ព័ន្ធដោយព្រាងចំណុចសំខាន់ៗនៃដំណើរការដែលជនចំណាកស្រុក និងអតីតជនរងគ្រោះបានឆ្លងកាត់ចាប់ពីពេលដែលពួកគេចង់ធ្វើចំណាកស្រុកដំបូង រហូតទៅដល់ចំណុចដែលពួកគេទៅដល់គោលដៅធ្វើការ។ការធ្វើដំណើរត្រូវបំបែកចេញជាជំហានៗដោយកំណត់ឥរិយាបថសុវត្ថិភាពនិងគ្រោះថ្នាក់នៅក្នុងជំហាននីមួយៗ។លទ្ធផលនឹងជួយបង្ហាញចំណុចដូចជា៖

- **កត្តាភាពងាយរងគ្រោះ៖** តើបណ្តុំចំណេះដឹងអាកប្បកិរិយា ឥរិយាបថ ប្រជាសាស្ត្រនិងកត្តាសេដ្ឋកិច្ចអ្វីខ្លះដែលធ្វើអោយជនចំណាកស្រុកងាយនឹងត្រូវគេជួញដូរ?
- **កត្តាបង្កហានិភ័យ៖** តើនៅក្នុងស្ថានភាពអ្វីនិងនៅចំណុចណាក្នុងការធ្វើដំណើរដែលជនចំណាកស្រុកភាគច្រើនងាយនឹងត្រូវគេជួញដូរ
- **ការផ្សារភ្ជាប់៖** សំនួរសំខាន់បំផុតដែលត្រូវសួរនោះគឺថាតើភាពងាយរងគ្រោះអាចភ្ជាប់ទៅនឹងហានិភ័យបានដែរឬយ៉ាងណា ។ ជាបញ្ហាដែលអ្នកងាយរងគ្រោះកាន់តែច្រើនទំនងជាត្រូវបានជួញដូរតាំងពីនៅកន្លែងដំបូង។

ឆ្លើយនឹងសំនួរទាំងនេះនឹងជួយកម្មវិធីទប់ស្កាត់ពាក់ព័ន្ធនឹង៖

- បង្កើតសារសំខាន់ៗសម្រាប់ការទំនាក់ទំនង
- កាន់តែច្បាស់លាស់អំពីកន្លែងនិងពេលវេលាដែលត្រូវទប់ស្កាត់
- ផ្តោតការយកចិត្តទុកដាក់ខ្លាំង លើសកម្មភាពដែលអាចជួយក្នុងការពង្រឹងឥរិយាបថសម្រាប់ចំណាកស្រុកដោយសុវត្ថិភាព។

## ក្រុមគោលដៅ

**ការសិក្សាភាពងាយរងគ្រោះ** កំណត់គោលដៅលើមនុស្សដែលងាយនឹងត្រូវគេជួញដូរ។ លក្ខណៈវិនិច្ឆ័យគោលដៅមានដូចខាងក្រោម ៖

- បែងចែក៥០/៥០រវាងមនុស្សប្រុសនិងមនុស្សស្រី
- មានកំណត់អាយុពី១៨ទៅ៣៥ឆ្នាំ
- នៅក្នុងចំណាត់ថ្នាក់សង្គមសេដ្ឋកិច្ចទាប (SES DE)ជាក្រុមមនុស្សដែលពេលខ្លះមិនមានលទ្ធភាពទិញសម្លៀកបំពាក់ថ្មី ឬចំណីអាហារ
- មានបំណងចង់ចំណាកស្រុកទៅបរទេសឬទៅខេត្តដទៃនៅក្នុងប្រទេសកម្ពុជា
- មិនធ្លាប់ធ្វើចំណាកស្រុកទៅបរទេសឬទៅកាន់ខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជាពីមុន។

**ជនចំណាកស្រុកដែលវិលត្រឡប់**គឺ ជាអ្នកដែលបានធ្វើចំណាកស្រុកជោគជ័យដោយមិនត្រូវបានគេជួញដូរ៖

- បែងចែក៥០/៥០រវាងមនុស្សប្រុសនិងមនុស្សស្រី

- បានធ្វើចំណាកស្រុកក្នុងប្រទេសឬក្រៅប្រទេសដើម្បីធ្វើការនៅក្នុងរយៈពេល១២ខែចុងក្រោយ ហើយបានត្រឡប់មកផ្ទះវិញដោយមិនមានជំនួយ
- មានអាយុ១៨ឆ្នាំឬលើស

**អតីតជនរងគ្រោះ**គឺជាមនុស្សដែលធ្លាប់បានគេជួញដូរ មិនថានៅក្នុងប្រទេសឬនៅក្រៅប្រទេស៖

- បែងចែក៥០/៥០រវាងមនុស្សប្រុសនិងមនុស្សស្រី
- ធ្លាប់បានគេជួញដូរនៅក្នុងប្រទេសកម្ពុជាឬនៅបរទេស
- មានអាយុ១៨ឆ្នាំឬលើស

## គំរូចំនួនអ្នកងាយរងគ្រោះ

ខេត្តចំនួន៧ត្រូវបានកំណត់ថាជាតំបន់ប្រភពនៃអំពើជួញដូរមនុស្ស។ ដោយផ្អែកលើអនុសាសន៍ពីបណ្តាអង្គការដែលធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនានា ស្រុកនិងភូមិដែលជា"ចំណុចក្តៅ" មួយចំនួនត្រូវបានរកឃើញនៅក្នុងខេត្តទាំងនេះ។ នៅក្នុងភូមិនីមួយៗ គេជ្រើសរើសគ្រួសារដោយប្រើវិធីដើរចូលដោយចៃដន្យដោយជ្រើសរើសរៀងរាល់គ្រួសារទីបី ។ នៅក្នុងគ្រួសារអ្នកឆ្លើយម្នាក់ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យចំនួនកំណត់។

នៅខេត្តបន្ទាយមានជ័យភូមិមួយចំនួនដែលបានជ្រើសរើសត្រូវបានជំនួស ។ ដោយសារតែចំណាកស្រុកទៅកាន់ប្រទេសថៃមានកម្រិតខ្ពស់ ទើបមិនអាចស្វែងរកអ្នកឆ្លើយដែលមិនធ្លាប់ធ្វើចំណាកស្រុកពីមុនអោយបានគ្រប់ចំនួន។

| ខេត្ត | ស្រុក/ភូមិ | ចំនួនគំរូ |
|---|---|---|
| ភ្នំពេញ | ខណ្ឌដង្កោឬស្សីកែវមានជ័យសែនសុខចំការមនដង្កោរ ពោធិ៍សែនជ័យ | ១០០ |
| ស្វាយរៀង | ចន្ទ្រា | ១០០ |
| ព្រៃវែង | មេសាងដងហ្សរមេសាង | ១០០ |
| កោះកុង | ស្រែអំបិលស្មាច់មានជ័យ | ១០០ |
| សៀមរាប | វ៉ារិន | ១០០ |
| បន្ទាយមានជ័យ | មង្គលបូរីសេរីសោភ័ណ្ឌ | ១០០ |
| កំពង់ចាម | ស្រុកពញាក្រែក | ១០០ |
| សរុប | | ៧០០ |

## ការជ្រើសរើសថែជន្សសម្រាប់ខ្សែចង្វាក់ផ្ដត់ផ្ដង់

ជនចំណាកស្រុកកាលពីមុនត្រូវបានជ្រើសរើសនៅក្នុងភូមិតែមួយ និងក្រុមងាយរងគ្រោះដោយប្រើប្រាស់មធ្យោបាយជ្រើសរើសថែជន្សនិងប្រព័ន្ធចំនួនកំណត់។អតីតជនរងគ្រោះត្រូវបានកំណត់ទាំងនៅក្នុងមណ្ឌលនិងសហគមន៍ជាម្ចាស់ផ្ទះ។នៅក្នុងចំណោមអ្នកឆ្លើយសំណួរ៦០នាក់ដែលបានសម្ភាសន៍រួមផ្សំដោយស្ត្រី៣៦នាក់នៅក្នុងមណ្ឌលនិងបុរស២៤នាក់នៅក្នុងសហគមន៍ជាម្ចាស់ផ្ទះ។

ការស្វែងរកអតីតជនរងគ្រោះដើម្បីសម្ភាសន៍មិនងាយស្រួលនោះទេ ។ មណ្ឌលមួយចំនួនបដិសេធក្នុងការសហការមណ្ឌលដទៃទៀតមានអតីតជនរងគ្រោះតែពីរបីនាក់ប៉ុណ្ណោះហើយអតីតជនរងគ្រោះមួយចំនួនមានការប៉ះពាល់ផ្លូវចិត្ត និងមិនអាចធ្វើការសម្ភាសន៍បាន។ នៅក្នុងមណ្ឌលមួយចំនួនកិច្ចសម្ភាសន៍មួយចំនួនត្រូវបញ្ឈប់ដោយសារអតីតជនរងគ្រោះដែលត្រូវបានសម្ភាសន៍ ក្លាយទៅជាអ្នកដែលមិនធ្លាប់ត្រូវគេជួញដូរ។

| ខេត្ត | ស្រុក/ភូមិ | ចំនួនគំរូជនចំណាកស្រុកដែលវិលត្រឡប់ | ចំនួនគំរូអ្នកដែលរួចខ្លួន |
|---|---|---|---|
| ភ្នំពេញ | ខណ្ឌដង្កោឫស្សីកែវមានជ័យសែនសុខ ចំការមនដង្កោរ ពោធិ៍សែនជ័យ | ៣០ | ១១ |
| ស្វាយរៀង | ចន្ទ្រា | ៣០ | ៤ |
| ព្រៃវែង | មេសាងដងហ្សរមេសាង | ៣០ | ៧ |
| កោះកុង | ស្រែអំបិលស្មាច់មានជ័យ | ៣០ | ១០ |
| សៀមរាប | វ៉ារិន | ៣០ | ៧ |
| បន្ទាយមានជ័យ | មង្គលបូរីសេរីសោភ័ណ្ឌ | ៣០ | ៧ |
| កំពង់ចាម | ស្រុកពញាក្រែក | ៣០ | ១៤ |
| សរុប | | ២១០ | ៦០ |

◇◇◇◇◇◇◇◇◇◇◇◇◇◇◇◇

# ព័ត៌មានក្រុមគោលដៅ

**ព័ត៌មានប្រជាសាស្ត្រនិងសេដ្ឋកិច្ចរបស់ក្រុមងាយរងគ្រោះជនចំណាកស្រុកនិងអតីតជនរងគ្រោះក៏ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ។**

## ព័ត៌មានប្រជាសាស្ត្រ

នៅក្នុងក្រុមងាយរងគ្រោះភាគច្រើនបានបញ្ចប់បឋមសិក្សា ឬតិចជាងនេះ ។ មានតែពាក់កណ្ដាលប៉ុណ្ណោះដែលមានការងារធ្វើមានរបរផ្ទាល់ខ្លួនការងារតាមរដូវឬការធ្វើកសិកម្មចិញ្ចឹមជីវិត ។ មានភាពខុសគ្នាមួយចំនួនរវាងជនចំណាកស្រុកដែលវិលត្រឡប់និងអតីតជនរងគ្រោះ។ អតីតជនរងគ្រោះទំនងជាមានវ័យក្មេងហើយមានកម្រិតវប្បធម៌ទាប ។ ចំណុចលើកឡើងពីសារសំខាន់នៃការអប់រំនិងបន្តអោយកុមារទៅរៀន ។ កម្មវិធីនានាដែលជំរុញកត្តានេះក៏ជួយកាត់បន្ថយអំពើជួញដូរមនុស្សផងដែរ។

| ព័ត៌មាន | ជនងាយរងគ្រោះ n=៧០០ (%) | ជនចំណាកស្រុកដែលវិលត្រឡប់ n=២១០ (%) | អតីតជនរងគ្រោះ n=៦០ (%) |
|---|---|---|---|
| ភេទ (ភាគកំណត់) | | | |
| ប្រុស | ៥០ | ៥០ | ៤០ |
| ស្រី | ៥០ | ៥០ | ៦០ |
| អាយុ (ភាគកំណត់) | | | |
| ១៨-១៩ | ២៩ | ៩ | ៦៦ |
| ២០-២៤ | ២៩ | ៣១ | ២០ |
| ២៥-២៩ | ២៨ | ៣៣ | ៧ |
| ៣០-៣៩ | ១៤ | ២៧ | ៧ |
| ការអប់រំ | | | |
| ត្រឹមបឋមសិក្សា | ៧១ | ៦៨ | ៨៣ |
| អនុវិទ្យាល័យ | ២៣ | ២២ | ១៥ |
| វិទ្យាល័យ | ៦ | ១០ | ២ |
| ឧត្តមសិក្សា ឬខ្ពស់ជាង | - | - | - |
| សកម្មភាពបច្ចុប្បន្ន | | | |
| សិក្សា | ២៧ | ១២ | ៣៥ |
| ធ្វើការរកស៊ីធ្វើការតាមរដូវ។ល។ | ៥៧ | ៧៥ | ៤៧ |
| ធ្វើកិច្ចការផ្ទះ | ១៣ | ១០ | ១០ |
| គ្មានការងារធ្វើ/ផ្សេងៗ | ៣ | ៣ | ៨ |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# ព័ត៌មានសេដ្ឋកិច្ច

ស្ថានភាពសង្គមសេដ្ឋកិច្ច (SES) ត្រូវបានកំណត់ន័យថា៖ ពេលខ្លះមិនមានលទ្ធភាពទិញ :

E – ចំណីអាហារ

D – សំលៀកបំពាក់ថ្មី

ABC – អ្នកដែលមានជីវភាពគ្រាន់បើ

អតីតជនរងគ្រោះស្ទើរពាក់កណ្តាលស្ថិតនៅក្នុងចំណាត់ថ្នាក់ ស្ថានភាពសង្គមសេដ្ឋកិច្ចកំរិត E ។ សន្តិសុខស្បៀងគឺជាកត្តាសេដ្ឋកិច្ចសំខាន់ដែលបែងចែកក្រុមនីមួយៗ អោយខុសពីគ្នា។ អតីតជនរងគ្រោះមានជីវភាពយ៉ាប់យឺនដែលមួយចំនួនមានដីផ្ទាល់ខ្លួននិងមួយចំនួនទៀតមានអង្ករហូបគ្រប់គ្រាន់ដោយខ្លួនឯង ។ ដូច្នេះកម្មវិធីដែលពាក់ព័ន្ធនឹងការកែលម្អសន្តិសុខចំណីអាហារ អាចចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបញ្ឈប់អំពើជួញដូរមនុស្ស។

| ព័ត៌មាន | ជនងាយរងគ្រោះ n=700 (%) | ជនចំណាកស្រុកដែលវិលត្រឡប់ n=210 (%) | អតីតជនរងគ្រោះ n=60 (%) |
|---|---|---|---|
| ធ្វើស្រែខ្លួនឯង | | | |
| បាទ/ចាំ មានដី | 87 | 69 | 67 |
| បាទ/ចាំជួលដី | 3 | 1 | 3 |
| ទេ | 10 | 30 | 30 |
| ទិញ ឬខ្ចីអង្ករ | | | |
| ផ្គត់ផ្គង់ខ្លួនឯង | 40 | 31 | 17 |
| ១ – ៣ខែ | 29 | 16 | 17 |
| ៤ – ៦ខែ | 13 | 10 | 19 |
| ៧ – ១២ខែ | 18 | 43 | 45 |
| ជាមធ្យម | 3 ខែ | 6 ខែ | 7 ខែ |
| IDកាតក្រីក្រ | | | |
| ID ក្រីក្រ១ | 9 | 8 | 18 |
| ID ក្រីក្រ២ | 12 | 14 | 8 |
| គ្មាន | 79 | 78 | 73 |
| ចំណូល | | | |
| សមាមាត្រសមាជិកគ្រួសារដែលផលិតចំណូល | 44% | 47% | 45% |
| ស្ថានភាពសេដ្ឋកិច្ច | | | |
| E | 24 | 24 | 47 |
| D | 76 | 76 | 53 |
| ABC | - | - | - |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# វិស័យការងារ - សម្រាប់តែប្រភេទអ្នកងាយរងគ្រោះប៉ុណ្ណោះ

ភាគច្រើននៃប្រភេទអ្នកងាយរងគ្រោះ ធ្វើការក្នុងវិស័យកសិកម្មបន្ទាប់មកគឺការងារចម្រុះនៅក្នុងវិស័យដទៃទៀត។




*មូលដ្ឋាន៖អ្នកងាយរងគ្រោះទាំងអស់ដែលមានការងារធ្វើ*

# ប្រភេទការងារចំណាកស្រុក

ទាំងជនចំណាកស្រុកនិងអតីតជនរងគ្រោះដែលបានសម្ភាសន៍ធ្លាប់ធ្វើការងារនៅក្នុងវិស័យខុសៗគ្នាជាច្រើនដូចជាសំណង់រោងចក្រនេសាទនិងកំសាន្ត ។ នេសាទកសិកម្មនិងកំសាន្តលេចធ្លោជាងគេដោយសារវិស័យនេះទាក់ទាញមនុស្សភាគច្រើន ដែលត្រូវបានជួញដូរបើប្រៀបធៀបនឹងជនចំណាកស្រុកដែលវិលត្រឡប់ ។ ឧទាហរណ៍វិស័យនេសាទនៅប្រទេសថៃគឺត្រូវបានគេស្គាល់យ៉ាងច្បាស់ថាកេងប្រវ័ញ្ចកម្មករដែលទៅពីប្រទេសកម្ពុជាជាពិសេសបុរស។

# ជនចំណាកស្រុកវិលត្រឡប់និងអតីតជនរងគ្រោះ

## ការដាក់បញ្ចូលប្រព័ន្ធផ្សព្វផ្សាយ




*មូលដ្ឋាន៖ជនចំណាកស្រុកនិងអតីតជនរងគ្រោះទាំងអស់*

ទូរទស្សន៍និងវិទ្យុគឺជាប្រព័ន្ធព័ត៌មានដែលមនុស្សភាគច្រើនអាចមានលទ្ធភាពទទួលបាន ។ ប្រព័ន្ធផ្សព្វផ្សាយមានភាគរយខ្ពស់បំផុតសម្រាប់ជនចំណាកស្រុកវិលត្រឡប់និងទាបបំផុតសម្រាប់អតីតជនរងគ្រោះ ។ នៅក្នុងចំណាត់ថ្នាក់អ្នកងាយរងគ្រោះមនុស្សម្នាក់នៅក្នុងចំណោមមនុស្សប្រាំនាក់មិនអាចទទួលបានប្រព័ន្ធផ្សព្វផ្សាយណាទាំងអស់។ នេះមិនមែនជារឿងភ្ញាក់ផ្អើលឡើយដែលការមើលឃើញពីស្ថានភាពសង្គមសេដ្ឋកិច្ចទាបរបស់អតីតជនរងគ្រោះក៏ថែមទាំងរំលេចពីបញ្ហាប្រឈមលើកម្មវិធីទប់ស្កាត់ដែលពឹងផ្អែកលើប្រព័ន្ធផ្សព្វផ្សាយទូទៅ ។ យ៉ាងហោចណាស់មួយភាគបីនៃអតីតជនរងគ្រោះមិនអាចទទួលបានប្រព័ន្ធផ្សព្វផ្សាយធម្មតា។

## ការដាក់បញ្ចូលទូរស័ព្ទចល័ត




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

ការដាក់បញ្ចូលទូរស័ព្ទចល័តនៅក្នុងក្រុមអ្នកងាយរងគ្រោះមានចំនួន ៥៨%បន្ទាប់មក ៥៦% សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់និង ៣៥%សម្រាប់អតីតជនរងគ្រោះ។ ជាថ្មីម្តងទៀតនេះគឺជាការឆ្លុះបញ្ចាំងអោយឃើញពីស្ថានភាពងាយរងគ្រោះ សម្រាប់អ្នកដែលត្រូវបានកំណត់គោលដៅ ដោយអ្នកជួញដូរដោយសារពួកគេមានមធ្យោបាយតិចតួច ក្នុងការទំនាក់ទំនងជាមួយអ្នកដទៃដើម្បីស្វែងរកជំនួយ្ទានឬប្រមូលព័ត៌មាន។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# ការយល់ដឹងនិងបទពិសោធន៍ជាមួយអំពើជួញដូរមនុស្ស

### វិសាលភាពដែលអ្នកទទួលផលប្រយោជន៍បានដឹងពីអំពើជួញដូរមនុស្សការបង្ហាញទៅនឹងការធ្វើចំណាកស្រុក និងអន្តរាគមន៍អំពើជួញដូរមនុស្សកាលពីមុន

## យល់ដឹងពីអំពើជួញដូរមនុស្ស

មនុស្សស្ទើតែគ្រប់គ្នាបានលឺពីអំពើជួញដូរមនុស្សប៉ុន្តែមានមនុស្សតិចតួចប៉ុណ្ណោះដែលដឹងគួរសមពីបញ្ហានេះ ។ ការយល់ដឹងមានកម្រិតទាបនៅក្នុងក្រុមអ្នកងាយរងគ្រោះហើយរំលេចពីតម្រូវការសកម្មភាពលើកកម្ពស់ការយល់ដឹងដែលបានកំណត់គោលសម្រាប់ក្រុមនេះ។ទូរទស្សន៍គឺជាប្រភពចម្បងនៃការយល់ដឹងសម្រាប់អ្នកងាយរងគ្រោះនិងជនចំណាកស្រុក។អតីតជនរងគ្រោះដែលទទួលប្រព័ន្ធផ្សព្វផ្សាយតិចបានលឺពីអំពើជួញដូរមនុស្សតាមមិត្តភក្តិ និងឈានទៅរកវិសាលភាពធំជាងនេះ។

កម្រិតយល់ដឹង




ប្រភពការយល់ដឹង (មូលដ្ឋានៈអ្នកដែលដឹង)

| ប្រភពប្រព័ន្ធផ្សព្វផ្សាយ | អ្នកងាយរងគ្រោះ % | ជនចំណាកស្រុកវិលត្រឡប់ % | អតីតជនរងគ្រោះ % |
|---|---|---|---|
| សារព័ត៌មាន និងរបាយការណ៍ផ្សព្វផ្សាយ | 51 | 52 | 23 |
| ឯកសារតាមទូរទស្សន៍ | 53 | 45 | 50 |
| អានសៀវភៅ | 3 | 4 | 8 |
| តាមមិត្តភក្តិ | 30 | 58 | 62 |
| តាមអាជ្ញាធរមូលដ្ឋាន | 11 | 20 | 7 |
| អ៊ិនធឺណិត | 1 | - | - |
| ខ្សែភាពយន្ត | 6 | 4 | 5 |
| ការប្រកាសសេវាសាធារណៈ | 16 | 9 | 10 |
| សកម្មភាពសហគមន៍ | 7 | 5 | 5 |
| ប័ណ្ណប្រកាស ខិតប័ណ្ណ ឬកូនសៀវភៅផ្សព្វផ្សាយ | 5 | 2 | 8 |
| **ចំនួនប្រភពជាមធ្យម** | **1.8** | **2.0** | **1.8** |

*មូលដ្ឋានៈអ្នកចូលរួមទាំងអស់*

## ស្គាល់ជនដែលបានធ្វើចំណាកស្រុក

ប្រហែលមួយភាគបីនៅក្នុងក្រុមនីមួយៗស្គាល់នរណាម្នាក់ដែលធ្លាប់ធ្វើចំណាកស្រុក ។ សមាមាត្រមានភាគរយខ្ពស់ជាងសម្រាប់ជនចំណាកស្រុកនិងអតីតជនរងគ្រោះ។ នៅក្នុងករណីភាគច្រើនបុគ្គលដែលធ្វើចំណាកស្រុកត្រូវជាសាច់ញាតិ ឬបងប្អូន។ សម្រាប់អតីតជនរងគ្រោះវង្វង់ទំនាក់ទំនងអ្នកធ្វើចំណាកស្រុកទំនងជាមានលក្ខណៈទូលំទូលាយ។ដោយមានការប្រឈមខ្លាំងសម្រាប់ជនចំណាកស្រុកដលៃភាគច្រើនជាសមាជិកគ្រួសារដលៃអាចអោយប៉ាន់សុមានថាជនចំណាកសុរុកកាលពីមុនអាចជាកត្តាជះឥទ្ធិពលចម្បង ។ ដូច្នេះទស្សនាទាននៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពគឺជាចំណុចដែលត្រូវបង្រៀនទៅដល់មនុស្សគ្រប់គ្នាមិនត្រឹមតែសម្រាប់ជនចំណាកស្រុកលើកទីមួយប៉ុណ្ណោះទេ។

ស្គាល់បុគ្គលដែលបានធ្វើចំណាកស្រុក




ប្រភេទទំនាក់ទំនង

| បុគ្គល | អ្នកងាយរងគ្រោះ % | ជនចំណាកស្រុកវិលត្រឡប់ % | អតីតជនរងគ្រោះ % |
|---|---|---|---|
| ឪពុក | 1 | 2 | 7 |
| ម្ដាយ | <1 | 2 | 5 |
| បងប្អូនស្រី ឬប្រុស | 18 | 18 | 12 |
| សាច់ញាតិដទៃ | 10 | 13 | 7 |
| មិត្តជិតស្និទ្ធ | 2 | 4 | 10 |
| មិត្តរួមការងារ | <1 | <1 | 3 |

*មូលដ្ឋានៈអ្នកចូលរួមទាំងអស់*

## ទីសំចតរបស់ជនចំណាកស្រុក

ក្នុងចំណោមមនុស្សដែលបានធ្វើចំណាកស្រុកក្នុងរយៈពេល១២ខែចុងក្រោយ មួយភាគធំកំពុងតែនៅបរទេសនៅឡើយប៉ុន្តែទាក់ទងមកគ្រួសារ ឬមិត្តភក្តិជាធម្មតាហើយមួយចំនួនទៀតបានត្រឡប់មកផ្ទះវិញប្រកបដោយសុវត្ថិភាព។ មានករណីចំនួន ៨ (ដែលក្នុងនោះ៧ករណីទាក់ទងនឹងអតីតជនរងគ្រោះ) នៅក្នុងកាលៈទេសៈដែលមនុស្សម្នាក់អាចសង្ស័យថាបានធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។ ប៉ុន្តែមិនមាននរណាម្នាក់បានទាក់ទងនគរបាលដើម្បីរាយការណ៍អំពីបុគ្គលដែលបាត់ខ្លួនឡើយ។

| ទីកន្លែង | អ្នកងាយរងគ្រោះ n=198 (%) | ជនចំណាកស្រុកដែលវិលត្រឡប់ n=69 (%) | អតីតជនរងគ្រោះ n=21 (%) | លទ្ធផលរំពឹងទុក |
|---|---|---|---|---|
| ត្រឡប់មកផ្ទះដោយសុវត្ថិភាព | 15 | 36 | 24 | ទំនងជាចំណាកស្រុកប្រកបដោយសុវត្ថិភាព |
| នៅបរទេសតែនៅទាក់ទងធម្មតាមកពួកយើង | 66 | 48 | 38 | |
| នៅបរទេសហើយមិនទាក់ទងមកយើងជាធម្មតា | 19 | 15 | 5 | |
| នៅបរទេសប៉ុន្តែមិនបានលឺដំណឹងសោះ ហើយយើងបារម្ភ | - | 1 | 19 | ចំណាកស្រុកគ្មានសុវត្ថិភាព និងអាចជាអំពើជួញដូរមនុស្ស ក្នុងចំណោម ៨ ករណីគ្មានករណីណាមួយត្រូវបានរាយការណ៍ទៅនគរបាលឡើយ |
| មិនដឹងថាពួកគេនៅទីណា ហើយយើងកំពុងព្រួយបារម្ភ | - | - | 10 | |
| យើងសង្ស័យថា ពួកគេត្រូវបានជួញដូរ ឬបាត់ខ្លួន | - | - | 5 | |

*មូលដ្ឋានៈស្គាល់អ្នកដែលបានធ្វើចំណាកស្រុក*

# ការបង្ហាញពីអន្តរាគមន៍លើអំពើជួញដូរមនុស្សពីមុន

ប្រមាណមនុស្សម្នាក់ក្នុងចំណោមមនុស្សបួននាក់ឬប្រាំនាក់នៅក្នុងប្រភេទនីមួយៗត្រូវបានបង្ហាញពីអន្តរាគមន៍លើអំពើជួញដូរមនុស្សពីមុន។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពដែលអាចទៅដល់មានកម្រិតទាបបំផុតសម្រាប់អតីតជនរងគ្រោះ ។ ជាថ្មីម្តងទៀតចំណុចនេះបញ្ជាក់ថាជាបញ្ហានៃការដាក់បញ្ចូលប្រព័ន្ធផ្សព្វផ្សាយបានទាបសម្រាប់ប្រភេទអតីតជនរងគ្រោះ ។ ប្រភេទអន្តរាគមន៍ដែលសាមញ្ញបំផុត គឺការប្រជុំសហគមន៍ ឬប្រភេទប្រព័ន្ធផ្សព្វផ្សាយទូទៅមួយចំនួន។

ការបង្ហាញពីអន្តរាគមន៍ TIP ពីមុន

(ប្រភព៖ អ្នកដែលដឹងពី TIP )




ប្រភេទសកម្មភាពដែលបានបង្ហាញ

(ប្រភព៖ អ្នកដែលបានបង្ហាញ )

| សកម្មភាព | អ្នកងាយរងគ្រោះ n=164 (%) | ជនចំណាកស្រុកដែលវិលត្រឡប់ n=50 (%) | អតីតជនរងគ្រោះ n=12 (%) |
|---|---|---|---|
| យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយទូទៅ | 37 | 18 | 42 |
| សកម្មភាពសហគមន៍ | 21 | 18 | 8 |
| ការចែកចាយព័ត៌មាន | 11 | 4 | 25 |
| ប្រជុំសហគមន៍ | 44 | 62 | 33 |
| ផ្សេងៗ | 1 | - | - |

*មូលដ្ឋាន៖អ្នកដែលដឹងពីការជួញដូរមនុស្ស*

# កម្រិតនៃការចូលរួម

ការចូលរួមនៅក្នុងអន្តរាគមន៍ពីមុនគឺមានសង្គតិភាពណាស់សម្រាប់ក្រុមទាំងអស់ ។ ពីរភាគបីគឺជាអ្នកស្តាប់អកម្មហើយប្រហែលជាមនុស្សម្នាក់ក្នុងចំណោមប្រាំនាក់បានចូលរួមយ៉ាងសកម្ម ។ នៅក្នុងករណីការទំនាក់ទំនងទប់ស្កាត់រំលេចពីតម្រូវការលើការផ្តល់សារច្បាស់លាស់ ព្រមទាំងដើម្បីជំរុញទឹកចិត្តអោយចូលរួមយ៉ាងសកម្ម។




*មូលដ្ឋាន៖អ្នកដែលចូលរួមនៅក្នុងអន្តរាគមន៍ពីមុន*

# ក្របខ័ណ្ឌការវាយតម្លៃជាលក្ខណៈចក្ខុវិស័យ

## ការវាយតម្លៃដំណើរការនិងឥទ្ធិពលវាស់វែងជាមួយនឹងការផ្សារភ្ជាប់ទៅនឹងមធ្យោបាយផ្អែកលើសិទ្ធិមនុស្ស

## បញ្ហាប្រឈមក្នុងការវាយតម្លៃ

បញ្ហាប្រឈមចម្បងសម្រាប់កម្មវិធីប្រភេទទប់ស្កាត់ទាក់ទងនឹងអំពើជួញដូរមនុស្សគឺមិនអាចទៅរួចក្នុងការវាស់វែងដោយផ្ទាល់នូវលទ្ធផលចុងក្រោយនៃការកាត់បន្ថយចំនួនមនុស្សដែលត្រូវបានគេជួញដូរ មិនអាចទៅរួចក្នុងការបញ្ជាក់ពីអ្វីដែលយើងមិនដឹង! ដូច្នេះមានតម្រូវការខ្លាំងក្លាសម្រាប់ឧបករណ៍និងសូចនាករដែលអាចកំណត់វិសាលភាពដែលមនុស្សងាយរងគ្រោះនឹងអំពើជួញដូរមនុស្ស ។ សំខាន់បំផុតនោះគឺអាចធ្វើចំណាត់ថ្នាក់អ្នកទទួលផលប្រយោជន៍ទៅតាមកម្រិតហានិភ័យផ្សេងៗគ្នា គឺមានប្រយោជន៍បើគិតតាមទស្សនៈអន្តរាគមន៍តាមរយៈការប៉ុនប៉ងដែលត្រូវបានផ្តោតខ្លាំងកំណត់គោលដៅផ្អែកដែលត្រឹមត្រូវជាមួយនឹងសារដែលទាក់ទងអោយបានទាន់ពេលវេលា។

### មធ្យោបាយផ្អែកលើសិទ្ធិមនុស្ស

សម្រាប់ការសិក្សានេះអង្គការ Winrock International បានបង្កើតចំណុចដែលមានអ្នកទទួលផលចូលរួមក្នុងដំណើរការរួមមានសហគមន៍ដែលងាយរងគ្រោះ ជនចំណាកស្រុកកាលពីមុននិងអតីតជនរងគ្រោះពីការជួញដូរ ។ ចំណេះដឹងឥរិយាបថ និងអាកប្បកិរិយាសុទ្ធតែត្រូវបានវាយតម្លៃដោយការសម្ភាសន៍អ្នកទទួលផលចំនួនបីក្រុមដោយផ្ទាល់នៅនឹងកន្លែង ។ ព័ត៌មានដែលទទួលបានគួរតែមានប្រយោជន៍សម្រាប់ការអភិវឌ្ឍយុទ្ធសាស្រ្ត ទប់ស្កាត់នាពេលអនាគត និងការអភិវឌ្ឍសារដែលទាក់ទងនឹងសកម្មភាពទប់ស្កាត់ ។ ការយកចិត្តទុកដាក់យ៉ាងពិសេសត្រូវបានផ្តល់ទៅក្នុងការបង្កើតចំណុចគោល ដែលការទប់ស្កាត់នាថ្ងៃអនាគតអាចប្រៀបធៀបជាមួយបាន និងដកចេញនូវឥទ្ធិពលដែលមានសក្តានុពលទាំងឡាយ។

## ការអនុវត្តក្របខ័ណ្ឌ

RAPID ASIA
KAP SCORE

ក្រុមហ៊ុន Rapid Asia បានបង្កើតម៉ូដែលសម្រាប់តាមដាននិងវាយតម្លៃកម្មវិធី ( ពិន្ទុ KAP )។ ដោយ ឡែកពីអំពើជួញដូរមនុស្ស ពិន្ទុKAP ត្រូវបានប្រើប្រាស់លើប្រធានបទផ្សេងៗដូចជា ការអប់រំ ការធ្វើចំណាកស្រុក សុខភាព ជំនួយគ្រោះមហន្តរាយនិងការអភិរក្សសត្វព្រៃ។

ពិន្ទុ KAP ត្រូវបានបង្កើតឡើងដើម្បីអោយអង្គការ ឬម្ចាស់ជំនួយអាចតាមដាន និងវាយតម្លៃដោយឯករាជ្យនូវឥទ្ធិពលនៃកម្មវិធីពីពេលមួយទៅពេលមួយ និងនៅតាមតំបន់ឬប្រទេសផ្សេងៗគ្នា ។ ពិន្ទុ KAP ត្រូវបានធ្វើសុពលកម្មផ្ទៃក្នុង និងបានអះអាងថាជាមធ្យោបាយដែលល្អប្រសើរសម្រាប់ការផ្លាស់ប្តូរឥរិយាបថ។

- ការជួញដូរមនុស្ស
- ការធ្វើចំណាកស្រុក
- សុខភាព
- ការអប់រំ
- ជំនួយគ្រោះមហន្តរាយ
- ការអភិរក្សសត្វព្រៃ

## សំណួរពិន្ទុKAP

ផ្អែកលើការវាយតម្លៃកាលពីមុនជាច្រើនសម្រាប់អំពើជួញដូរមនុស្សក៏ដូចជាធាតុចូលពីអ្នកជំនាញសិទ្ធិមនុស្សសំណួរគោលមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់ម៉ូដែលពិន្ទុKAP។ ផ្អែកលើការវាយតម្លៃជាច្រើនកាលពីមុនលើអំពើជួញដូរមនុស្សក៏ដូចជាធាតុចូលពីអ្នកជំនាញសិទ្ធិមនុស្សសំណួរគន្លឹះមួយចំនួនត្រូវបានរៀបចំសម្រាប់ក្របខ័ណ្ឌពិន្ទុ KAP ។ សំណួរនីមួយៗបានលើកឡើងពីចំណេះដឹងជាក់លាក់ បញ្ហាផ្លាស់ប្តូរឥរិយាបថ ឬអាកប្បកិរិយាដែលត្រូវចំគោលដៅដែលអន្តរាគមន៍ជាច្រើនព្យាយាមទំនាក់ទំនង។

| KAP | ការវាស់វែង | សំនួរ/មតិយោបល់ |
|---|---|---|
| **ចំណេះដឹង** | **ដឹង ឬមិនដឹង** | • តើចំណុចអ្វីដែលរៀបរាប់ប្រាប់ច្បាស់បំផុតពីមនុស្សត្រូវបានគេជួញដូរ?<br>• តើអំពើជួញដូរមនុស្សកើតឡើងនៅកន្លែងណា?<br>• តើទម្រង់នៃការរំលោភបំពានឬការកេងប្រវ័ញ្ចបែបណាដែលផ្សារភ្ជាប់នឹងអំពើជួញដូរមនុស្ស?<br>• តើអ្នកណាខ្លះដែលប្រឈមនឹងហានិភ័យ?<br>• តើមនុស្សធ្លាក់ខ្លួនត្រូវបានគេជួញដូរយ៉ាងដូចម្តេច? |
| **អាកប្បកិរិយា** | **កម្រិតនៃការព្រមព្រៀង** | • អំពើជួញដូរមនុស្សមិនមែនជាបញ្ហាធំដុំនៅក្នុងប្រទេសនេះទេ<br>• មនុស្សដែលខ្ញុំស្គាល់និយាយថាមនុស្សដែលត្រូវគេជួញដូរសក្តិសមនឹងទទួលលទ្ធផលបែបនឹង<br>• ប្រសិនបើមនុស្សដែលត្រូវបានជួញដូរធ្លាប់មានជីវភាពក្រីក្រយ៉ាងហោចណាស់ពេលនេះគេមានការងារធ្វើ<br>• មនុស្សដែលខ្ញុំស្គាល់មិនខ្វល់ពីអំពើជួញដូរមនុស្សទេ<br>• មនុស្សដែលត្រូវបានគេជួញដូរ គឺដោយសារការសម្រេចចិត្តផ្ទាល់ខ្លួន |
| **ឥរិយាបថ (អនុវត្ត)** | **កម្រិតនៃការគោរពតាមច្បាប់/ការគោរពតាមច្បាប់រំពឹងទុក** | • រាយការណ៍ពីសកម្មភាពជួញដូរមនុស្សដែលសង្ស័យ<br>• ដឹងព័ត៌មានពីអំពើជួញដូរមនុស្ស<br>• អប់រំមិត្តភក្តិពីអំពើជួញដូរមនុស្ស<br>• អប់រំមិត្តភក្តិថាស្រីពេស្យាចារមួយចំនួនគឺជាមនុស្សដែលត្រូវបានគេជួញដូរដោយបង្ខំ<br>• ស្វែងរកដំបូន្មានឯករាជ្យអំពីការងារនៅបរទេស |

## ពិន្ទុ KAP

ការផ្លាស់ប្តូរឥរិយាបថដោយមិនមានផ្នត់គំនិតត្រឹមត្រូវអាចស្ថិតនៅបានរយៈពេលខ្លីនិងមិនមានលទ្ធផលចុងក្រោយប្រកបដោយចីរភាពឡើយ ។ ពិន្ទុ KAP ផ្អែកលើសំអាងដែលការផ្លាស់ប្តូរឥរិយាបថត្រូវទ្រទ្រង់ដោយចំណេះដឹងក៏ដូចជាការឥរិយាបថគាំទ្រ។

ក្របខ័ណ្ឌពិន្ទុ KAP មានធាតុសំខាន់ចំនួនបីសម្រាប់មើលលើឥទ្ធិពលដូចជា សន្ទស្សន៍ KAP បំណែងចែកហានិភ័យ និងជំនឿស៊ុប។




## ការវាស់វែងឥទ្ធិពល










- សន្ទស្ស KAP គឺជាសូចនាករដែលវាស់វែងចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយាត្រូវបានរួមបញ្ចូលដើម្បីបង្កើតជាសូចនាករលេខមួយ។ សន្ទស្ស KAP ជួយក្នុងការធ្វើការវាយតម្លៃដំបូងធៀបនឹងឥទ្ធិពលកម្មវិធីដែលអាចតាមដាន និងវាយតម្លៃ ។

- បំណែងចែកហានិភ័យបែងចែកអ្នកទទួលផលប្រយោជន៍ទៅជាផ្នែកទាប មធ្យម និងខ្ពស់ដោយផ្អែកលើដំណាក់កាលអភិវឌ្ឍផ្នត់គំនិតរបស់អ្នកទទួលផល។ បើសមាមាត្រក្រុមហានិភ័យខ្ពស់កាន់តែខ្ពស់ នោះតម្រូវការធ្វើអន្តរាគមន៍ក៏កាន់តែខ្ពស់ដែរ។

- ជំនឿស៊ុបពិនិត្យលើឥរិយាបថ និងរបៀបក្នុងការសម្របសារទំនាក់ទំនងទៅកាន់បទដ្ឋានសង្គម និងគុណតម្លៃផ្ទាល់ខ្លួន។

## បំណែងចែកហានិភ័យ

អ្នកទទួលផលប្រយោជន៍មិនថានៅខាងផ្គត់ផ្គង់ ឬខាងតម្រូវការនោះទេអាចបែងចែកជាបីផ្នែកហា-និភ័យផ្អែកលើដំណាក់កាលអភិវឌ្ឍរបស់ពួកគេះហានិភ័យទាប មធ្យម និងខ្ពស់។ ចំនួនប្រជាជន ឬតំបន់ដែលមានសមាមាត្រហានិភ័យខ្ពស់គួរកំណត់អាទិភាពសម្រាប់ការទប់ស្កាត់នាថ្ងៃអនាគតដោយមានបំណងកាត់បន្ថយផ្នែកនេះអោយបានច្រើនបំផុតតាមដែលអាចធ្វើបាន។

| | ស្ថានភាព | យុទ្ធសាស្ត្រ |
|---|---|---|
| ហានិភ័យខ្ពស់ | មិនមានចំណេះដឹង ឬឥរិយាបថដែលចង់បាន ហើយពេលខ្លះមិនគាំទ្រដោយអាកប្បកិរិយាដែលចង់បាន។ | កំណត់អាទិភាពសម្រាប់ការទប់ស្កាត់នាថ្ងៃអនាគត |
| ហានិភ័យមធ្យម | អាចមានអាកប្បកិរិយាដែលចង់បាន ប៉ុន្តែមិនគាំទ្រដោយចំណេះដឹងនិង/ឬឥរិយាបថ ។ ក្រៅពីនេះមានតែចំណេះដឹងប៉ុណ្ណោះ។ | អប់រំ តាមដាន ពង្រឹងឥរិយាបថ |
| ហានិភ័យទាប | មានចំណេះដឹងដែលចង់បានហើយកំពុងកសាងឆ្ពោះទៅការផ្លាស់ប្តូរឥរិយាបថជាមួយនឹងការគាំទ្រពីឥរិយា-បថនិង/ឬអាកប្បកិរិយាដែលចង់បាន។ | កសាងភាពជោគជ័យនិងធ្វើសារជាថ្មី |

# ការវាយតម្លៃភាពងាយរងគ្រោះ

## ការកំណត់កត្តាភាពងាយរងគ្រោះដោយប្រើប្រាស់ពិន្ទុ KAP ក៏ដូចជាបទពិសោធន៍នៃកិច្ចខិតខំប្រឹងប្រែង

## សំនួរ KAP

បន្ថែមពីលើសំណួរពិន្ទុ KAP លើអំពើជួញដូរមនុស្ស សំណួរពិសេសមួយចំនួនអំពីការយល់ដឹង និងឥរិយាបថក៏ត្រូវបានសួរផងដែរ។

| KAP | ការវាស់វែង | សំនួរ/មតិយោបល់ |
|---|---|---|
| ការយល់ដឹង | ដឹង ឬមិនដឹង | • តើចំណុចអ្វីដែលរៀបរាប់ប្រាប់ច្បាស់បំផុតពីមនុស្សត្រូវបានគេជួញដូរ?<br>• តើអំពើជួញដូរមនុស្សកើតឡើងនៅកន្លែងណា?<br>• តើទម្រង់នៃការរំលោភបំពានឬការកេងប្រវ័ញ្ចបែបណាដែលផ្សាភ្ជាប់នឹងអំពើជួញដូរមនុស្ស?<br>• តើអ្នកណាខ្លះដែលប្រឈមនឹងហានិភ័យ?<br>• តើមនុស្សធ្លាក់ខ្លួនត្រូវបានគេជួញដូរយ៉ាងដូចម្តេច?<br>• តើចំណុចអ្វីដែលរៀបរាប់ប្រាប់ច្បាស់បំផុតអំពីការរត់ពន្ធមនុស្ស?<br>• ឯកសារចាំបាច់សម្រាប់ធ្វើការនៅបរទេស សំនួរពិសេស<br>• ផលវិបាកដោយសារមិនមានឯកសារការងារត្រឹមត្រូវ |
| អាកប្បកិរិយា | កម្រិតនៃការព្រមព្រៀង | • អំពើជួញដូរមនុស្សមិនមែនជាបញ្ហាធំដុំនៅក្នុងប្រទេសនេះទេ<br>• មនុស្សដែលខ្ញុំស្គាល់និយាយថាមនុស្សដែលត្រូវគេជួញដូរសក្តិសមនឹងទទួលលទ្ធផលបែបនឹង<br>• ប្រសិនបើមនុស្សដែលត្រូវបានជួញដូរធ្លាប់មានជីវភាពក្រីក្រយ៉ាងហោចណាស់ពេលនេះគេមានការងារធ្វើ<br>• មនុស្សដែលខ្ញុំស្គាល់មិនខ្វល់ពីអំពើជួញដូរមនុស្សទេ<br>• មនុស្សដែលត្រូវបានគេជួញដូរគឺដោយសារការជម្រើសផ្ទាល់ខ្លួន |
| ឥរិយាបថ (អនុវត្ត) | កម្រិតនៃការគោរពតាមច្បាប់/ការគោរពតាមច្បាប់រំពឹងទុក | • រាយការណ៍ពីសកម្មភាពជួញដូរមនុស្សដែលសង្ស័យ<br>• ដឹងព័ត៌មានពីអំពើជួញដូរមនុស្ស<br>• អប់រំមិត្តភក្តិពីអំពើជួញដូរមនុស្ស<br>• អប់រំមិត្តភក្តិថាស្រីពេស្យាចារមួយចំនួនគឺជាមនុស្សដែលត្រូវបានគេជួញដូរដោយបង្ខំ<br>• ស្វែងរកដំបូន្មានឯករាជ្យអំពីការងារនៅបរទេស |

## ការយល់ដឹង

ពាក់ព័ន្ធនឹងការយល់ដឹងមានគម្លាតបីជាចម្បង ។ ការយល់ដឹងដែលត្រឹមត្រូវអំពីអ្នកណាដែលជាក្រុមហានិភ័យទម្រង់ខុសគ្នានៃការកេងប្រវ័ញ្ចនិងយល់អំពីនិយមន័យនៃអំពើជួញដូរមនុស្ស ។ នេះបង្ហាញថាមនុស្សមិនសុាំនឹងទស្សនាទាននៃអំពើជួញដូរមនុស្សនិងមានន័យថាពួកគេអាចមិនស្គាល់អំពីស្ថានភាពហានិភ័យដែលមានសក្តានុពលទោះបីជាពួកគេបានដឹងក៏ដោយថាជនរងគ្រោះត្រូវបានគេបញ្ឆោត

ហើយថាអំពើជួញដូរកើតមាននៅក្នុងប្រទេសកម្ពុជា ។ ព័ត៌មានចំណេះដឹងគឺស្រដៀងគ្នាខ្លាំងនៅក្នុងផ្នែកទាំងបី។

## សមាមាត្រមនុស្សដែលមានការយល់ដឹង




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ការយល់ដឹងពីអំពើជួញដូរមនុស្ស

មានមនុស្សប្រមាណពាក់កណ្តាលប៉ុណ្ណោះដែលយល់ពីនិយមន័យត្រឹមត្រូវនៃអំពើជួញដូរមនុស្ស។ ក្រៅពីនេះមិនដឹងឬយល់ច្រឡំអំពើជួញដូឬជាមួយនឹងចំណាកស្រុកខុសច្បាប់ជនភៀសខ្លួន ឬការរត់ពន្ធមនុស្ស។ អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺអតីតជនរងគ្រោះមានការយល់ច្រឡំខ្លាំងរវាងអំពើជួញដូរជាមួយនឹងការរត់ពន្ធមនុស្ស ។ ការយល់ច្រឡំនេះត្រូវបានផ្សារភ្ជាប់ទៅនឹងអតីតជនរងគ្រោះដែលធ្លាក់ខ្លួនទៅជាប់បំណុលអ្នកជួញដូរ ។ ចំណុចនេះនាំអោយមានសំណួរថាតើមនុស្សយល់ដឹងពីបញ្ហាកេងប្រវ័ញ្ចកម្រិតណា។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ការយល់ដឹងអំពីការរត់ពន្ធមនុស្ស

អ្នកដែលមានការយល់ដឹងពីអំពើជួយដូរមនុស្ស ក៏ត្រូវបានសាកសួរផងដែរថាតើពួកគេស្គាល់អំពីនិយមន័យត្រឹមត្រូវអំពីការរត់ពន្ធមនុស្សដែរឬទេ។ ប្រហែលមួយភាគបីអាចស្គាល់យ៉ាងត្រឹមត្រូវអំពីនិយមន័យនេះហើយវាច្បាស់ណាស់ថា មនុស្សភាគច្រើនយល់ច្រឡំរវាងអំពើជួញដូរមនុស្ស និងការរត់ពន្ធមនុស្សដោយគិតថាដូចគ្នា។ ជាថ្មីម្តងទៀតអតីតជនរងគ្រោះទំនងជាមានការភាន់ច្រឡំកាន់តែខ្លាំងរវាងអំពើជួញដូរមនុស្សនិងការរត់ពន្ធមនុស្ស ។




*មូលដ្ឋាន៖អ្នកដែលដឹងពីការជួញដូរមនុស្ស*

## ឯកសារចាំបាច់ដើម្បីទៅធ្វើការនៅបរទេស

តើត្រូវការឯកសារអ្វីខ្លះដើម្បីទៅធ្វើការនៅបរទេសគឺជាបញ្ហាដែលមានការភាន់ច្រឡំខ្លាំង ។ មានមនុស្សតិចតួចប៉ុណ្ណោះដែលដឹងថា អ្នកត្រូវការលិខិតឆ្លងដែន ទិដ្ឋាការ និងលិខិតអនុញ្ញាតិការងារដើម្បីទៅធ្វើការនៅបរទេស។អតីតជនរងគ្រោះយល់ដឹងច្រើនជាងមុនបន្តិច ប៉ុន្តែមិនគ្រប់គ្រាន់ឡើយ។បញ្ហានេះគួរជាកង្វល់ដោយសារជនចំណាកស្រុក និងអតីតជនរងគ្រោះភាគច្រើនបាន ធ្វើចំណាកស្រុកទៅប្រទេសថៃដែលទិដ្ឋាការ និងលិខិតអនុញ្ញាតការងារគឺជាឯកសារដោយឡែកពីរផ្សេងគ្នានិងចេញដោយនាយកដ្ឋានពីរផ្សេងគ្នាដែរ។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# ផលវិបាកនៃឯកសារមិនត្រឹមត្រូវ

ប៉ុន្តែផលវិបាកនៃការមិនមានឯកសារត្រឹមត្រូវត្រូវបានដឹងច្បាស់។ សរុបមកប្រហែល៨០%មានការយល់ដឹងថាអ្នកអាចត្រូវចាប់ខ្លួននិងនិរទេសចេញ ។ ប៉ុន្តែដោយសារការយល់ដឹងអំពីឯកសារត្រឹមត្រូវមានកម្រិតទាប ការយល់ដឹងនេះទំនងជាមានឥទ្ធិពលតិចតួចទៅលើការធ្វើចំណាកស្រុកដោយសុវត្ថិភាព។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# ការវិភាគលើអាកប្បកិរិយា

អាកប្បកិរិយាត្រូវបានវាស់វែងដោយប្រើប្រាស់កម្រងសេចក្តីថ្លែងដែលត្រូវបានតាក់តែងយ៉ាងម៉ត់ចត់ដែលសេចក្តីថ្លែងនីមួយៗបង្ហាញអំពីអាកប្បកិរិយាពិសេសដូចមានបង្ហាញខាងក្រោម។ សេចក្តីថ្លែងត្រូវបានបង្កើតជាទម្រង់បុគ្គលទីបីដោយអនុញ្ញាតអោយអ្នកចូលរួមឆ្លើយអោយកាន់តែមានលក្ខណៈការពិតដោយមិនភ្ជាប់ខ្លួនឯងទៅនឹងអាកប្បកិរិយាពិសេស។

វិសាលភាពដែលប្រជាជនយល់ស្របឬមិនយល់ស្របចំពោះសេចក្តីថ្លែងបានកំណត់ថាតើអាកប្បកិរិយារបស់ខ្លួនមានលក្ខណៈអវិជ្ជមាន ឬវិជ្ជមានជាទូទៅ។

| សេចក្តីថ្លែង | អវិជ្ជមាន (ប្រសិនបើយល់ស្រប) | វិជ្ជមាន (ប្រសិនបើមិនយល់ស្រប) |
|---|---|---|
| អំពើជួញដូរមនុស្សមិនមែនជាបញ្ហាធំដុំនៅក្នុងប្រទេសនេះទេ | ការបដិសេធ | មិនមែនបដិសេធ |
| មនុស្សដែលខ្ញុំស្គាល់និយាយថា មនុស្សដែលត្រូវគេជួញដូរសក្តិសមនឹងទទួលលទ្ធផលបែបនឹង | បុរេវិនិច្ឆ័យ | មិនមែនបុរេវិនិច្ឆ័យ |
| ប្រសិនបើមនុស្សដែលត្រូវបានជួញដូរធ្លាប់មានជីវភាពក្រីក្រយ៉ាងហោចណាស់ពេលនេះគេមានការងារធ្វើ | ការរើសអើង | មិនរើសអើង |
| មនុស្សដែលខ្ញុំស្គាល់មិនខ្វល់ពីអំពើជួញដូរមនុស្សទេ | ភាពព្រងើយកន្តើយ | មិនព្រងើយកន្តើយ |
| មនុស្សដែលត្រូវបានគេជួញដូរគឺដោយសារការសម្រេចចិត្តផ្ទាល់ខ្លួន | ភាពមិនយកចិត្តទុកដាក់ | មិនមែនមិនយកចិត្តទុកដាក់ |

## អាកប្បកិរិយាវិជ្ជមាន

សេចក្ដីពណ៌នាទាំងស្រុងអំពីអាកប្បកិរិយាវិជ្ជមានស្រដៀងគ្នាយ៉ាងខ្លាំងនៅទូទាំងផ្នែកទាំងបី។ ប៉ុន្តែជនចំណាកស្រុកដែលវិលត្រឡប់ទំនងជាមានអាកប្បកិរិយាវិជ្ជមានជាងមុនបន្តិចបន្តួច ។ នៅលើផ្នែកវិជ្ជមាន មនុស្សជាច្រើនមិនមានការបដិសេធអំពីបញ្ហាជួញដូរមនុស្សទ ប៉ុន្តែអាកប្បកិរិយាផ្សេងៗទៀតទំនងជានៅលើផ្នែកដែលទាប។

### សមាមាត្រជាមួយអាកប្បកិរិយាវិជ្ជមានច្បាស់លាស់




*មូលដ្ឋានះគ្រប់អ្នកចូលរួមទាំងអស់*

## អាកប្បកិរិយាអវិជ្ជមាន

ជាថ្មីម្ដងទៀត សេចក្ដីពណ៌នាអំពីអាកប្បកិរិយាអវិជ្ជមានស្រដៀងគ្នាយ៉ាងខ្លាំងនៅទូទាំងផ្នែកទាំងបី។ អតីតជនរងគ្រោះទំនងជាកាន់តែមានអាកប្បកិរិយាជាងមុនបន្តិចបន្តួច ហើយអាចរងឥទ្ធិពលពីបទពិសោធន៍របស់ខ្លួន។ ការរើសអើងគឺជាអាកប្បកិរិយាអវិជ្ជមានដែលលេចធ្លោ ។ គំនិតនេះគឺថាមនុស្សដែលត្រូវបានជួញដូរអាចមានជីវភាពកាន់តែប្រសើរជាពិសេសប្រសិនបើគេមិនទាន់មានការងារធ្វើ។គួរអោយចាប់អារម្មណ៍ដែលថាអ្នករួចខ្លួនយល់ស្របនឹងគំនិតនេះ ទោះបីពួកគេធ្លាប់មានបទពិសោធន៍ក៏ដោយ។ នៅក្នុងករណីខ្លះនេះអាចជាទម្រង់នៃការបដិសេធដើម្បីបង្ហាញហេតុផលពីទង្វើរបស់ពួកគេ។

### សមាមាត្រជាមួយអាកប្បកិរិយាអវិជ្ជមានច្បាស់លាស់




*មូលដ្ឋានះអ្នកចូលរួមទាំងអស់*

## អាកប្បកិរិយាទូទៅ

ការពិតដែលថាមនុស្សជាច្រើននៅក្នុងផ្នែកងាយរងគ្រោះ យល់ស្របជាមួយសេចក្តីថ្លែងជាច្រើន បង្ហាញអំពីកម្រិតមិនត្រឹមត្រូវនៃសន្តិសុខដែលពួកគេមាន។ សេចក្តីថ្លែងចុងក្រោយជាពិសេស "ខ្ញុំកំពុងប្រឈមនឹងអំពើជួញដូរ" បង្ហាញយ៉ាងច្បាស់ថាមានមនុស្ស ៧០%មិនយល់ស្របមានន័យថាពួកគេមិនជឿថាខ្លួនឯងកំពុងប្រឈមនឹងអំពើជួញដូរ។

### ក្រុមងាយរងគ្រោះតែមួយគត់




*មូលដ្ឋានៈក្រុមងាយរងគ្រោះ*

## គោលបំណងឥរិយាបថ

ការស្វែងរកដំបូន្មានឯករាជ្យអំពីការងារក្រៅប្រទេសការមិនទាក់ទងភ្នាក់ងារដែលផ្តល់ព័ត៌មានមិនត្រឹមត្រូវការអប់រំមិត្តភក្តិអំពីបញ្ហាកន្លែងស្វែងរកព័ត៌មានពីអំពើជួញដូរមនុស្សមានការអនុវត្តតាមទាបជាង។ចំណុចនេះរួមជាមួយនឹងការពិតដែលថា មនុស្សជាច្រើនមិនដឹងថាតើត្រូវការឯកសារអ្វីខ្លះដើម្បីទៅធ្វើការនៅប្រទេសផ្សេងគឺជាភ័ស្តុតាងចំពោះកម្រិតងាយរងគ្រោះរបស់អ្នកទទួលផលដែលបានធ្វើសម្ភាសន៍។ជាការគួរអោយចាប់អារម្មណ៍នៅក្នុងការដឹងថាអតីតជនរងគ្រោះភាគច្រើននៅតែមិនយល់អំពីឥរិយាបថទប់ស្កាត់ទោះបីជាខ្លួនធ្លាប់ឆ្លងកាត់ក៏ដោយ។

### សមាមាត្រអ្នកដែលបង្ហាញថាខ្លួននឹងអនុវត្តតាមទាំងស្រុង




*មូលដ្ឋានៈអ្នកចូលរួមទាំងអស់*

## ប្រភពព័ត៌មានអំពីចំណាកស្រុកដោយសុវត្ថិភាព

អ្នកដែលបង្ហាញថាខ្លួនមិនដឹងអំពីទីកន្លែងស្វែងរកព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ត្រូវបានសាកសួរពីទីកន្លែងដែលពួកគេនឹងទៅស្វែងរក។ចម្លើយមានចម្រុះ ហើយអ្នកងាយរងគ្រោះទំនង ជាពឹងផ្អែកលើអង្គការមិនមែនរដ្ឋាភិបាល ចំណែកឯអតីតជនរងគ្រោះចូលចិត្តទៅរកអង្គការមិនមែន រដ្ឋាភិបាលមានតិចតួចប៉ុណ្ណោះដែលនឹងពឹងផ្អែកលើមេខ្យល់ ឬអ្នកទទួលបន្ត និងបង្ហាញថាប្រជាជន មានការយល់ដឹងអំពីសំណួរជាមុនហើយបានឆ្លើយដោយត្រឹមត្រូវ។

**អ្នកដែលបានបង្ហាញថាខ្លួនមិនដឹងជាត្រូវស្វែងរកព័ត៌មាននោះនៅកន្លែងណា**




*ប្រភព៖អ្នកនិយាយថាខ្លួនមិនដឹង*

## បទពិសោធន៍អំពីស្ថានភាពលំបាក

អ្នកចូលរួមត្រូវបានសាកសួរថា តើពួកគេ ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់ពួកគេ ធ្លាប់ឆ្លងកាត់ការ លំបាកក្នុងទម្រង់ណាមួយនៅក្នុងរយៈពេល ១២ខែចុងក្រោយដែរឬទេ ។ អ្នកងាយរងគ្រោះនិងជន ចំណាកស្រុកដែលវិលត្រឡប់ធ្លាប់មានបទពិសោធន៍ស្រដៀងគ្នា ហើយជាមធ្យមធ្លាប់ឆ្លងកាត់ទម្រង់ ខុសៗគ្នាចំនួនប្រហែល ២នៃការលំបាកក្នុងរយៈពេល ១២ឆ្នាំចុងក្រោយ។ អតីតជនរងគ្រោះជាមធ្យម ធ្លាប់ឆ្លងកាត់ទម្រង់ចំនួនជិតបីកន្លះនៃការលំបាក និងជំងឺបំណុលគ្រោះធម្មជាតិ ការបោះបង់ការសិក្សា ហើយការបែកបាក់គ្រួសារគឺជាកត្តាលំបាកដែលលេចធ្លោជាងគេ។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

# ការបែងចែកភាពងាយរងគ្រោះ

**ការកំណត់កម្រិតភាពងាយរងគ្រោះនិងការប្រៀបធៀបរវាងចំណែកខុសៗគ្នា ដោយប្រើប្រាស់ពិន្ទុ KAP**

## ឧបករណ៍វាស់ភាពងាយរងគ្រោះ

ភាពងាយរងគ្រោះអាចពិនិត្យមើលតាមវិធីពីរយ៉ាង។សន្ទស្សន៍ KAP គឺជាសូចនាករដែលការវាស់វែងការយល់ដឹងអាកប្បកិរិយានិងឥរិយាបថត្រូវបានបញ្ចូលគ្នាដើម្បីបង្កើតសូចនាករមួយលេខចំនួនមួយ។ សន្ទស្សន៍ KAP ត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបផ្នត់គំនិតទាំងមូលរវាងចំណែកខុសៗគ្នា។

ការបែងចែកហានិភ័យធ្វើការបែងចែកអ្នកទទួលផលជាចំណែកហានិភ័យទាប មធ្យម និងខ្ពស់ដោយផ្អែកលើដំណាក់កាលអភិវឌ្ឍន៍នៃផ្នត់គំនិតរបស់ពួកគេ។ ប្រសិនបើភាគរយដែលធ្លាក់ចំក្រុមហានិភ័យខ្ពស់ កាន់តែខ្ពស់នោះប្រជាជនក៏កាន់តែងាយរងត្រូវគេជួញដូរ ហើយក៏កាន់តែត្រូវការអន្តរាគមន៍ខ្លាំងជាងមុនដែរ។




## សន្ទស្សន៍ KAP ទូទៅនិងការបែងចែកហានិភ័យ

សន្ទស្សន៍ KAP នៅទូទាំងក្រុមទាំងបីពិតជាស្រដៀងគ្នាណាស់ទោះបីជាទាបជាងបន្តិចបន្តួចចំពោះក្រុមងាយរងគ្រោះដែលមាន 102 ក៏ដោយ។វាច្បាស់ណាស់ថាភាគច្រើននៃអ្នកដែលត្រៀមធ្វើចំណាកស្រុកដោយសុវត្ថិភាពនៅតែអាចប្រឈមនឹងហានិភ័យ។ ដូច្នេះឥរិយាបថធ្វើចំណាកស្រុកដោយសុវត្ថិភាពកម្រនឹងអនុវត្តតាមណាស់។ទីពីរការរួចផុតពីមេរៀនជូរចត់នៃអំពើជួញដូរមិនមែនជាបទពិសោធន៍មួយឡើយ ហើយអតីតជនរងគ្រោះជាច្រើននៅតែប្រឈមនឹងហានិភ័យ។លទ្ធផលនេះគឺថាប្រហែល 60 នៅក្នុងក្រុមនីមួយៗអាចចាត់ទុកថាជាហានិភ័យខ្ពស់ ហើយពិតជាត្រូវការអន្តរាគមន៍ទប់ស្កាត់ដែលកំណត់គោលដៅចំពោះគ្រប់ចំណែកទាំងបី។







*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## សន្ទស្សន៍ KAP តាមប្រជាសាស្ត្រ

សន្ទស្សន៍ KAP អាចប្រើប្រាស់ដើម្បីប្រៀបធៀបរវាងចំណែកទាំងបីដែលក្នុងករណីនេះពាក់ព័ន្ធនឹងអាយុនិងភេទ។សន្ទស្សន៍ KAP មានកម្រិតទាបជាងមួយចំនួនសម្រាប់ស្ត្រីបើប្រៀបធៀបជាមួយបុរស និងមានន័យថាស្ត្រីជាមធ្យមងាយរងគ្រោះជាង ។ ពុំមានគំរូពិតប្រាកដនៅទូទាំងអាយុក្រុមឡើយផ្ទុយមកវិញភាពងាយរងគ្រោះមានកម្រិតទាបដោយមិនគិតពីអាយុ។







*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

កម្រិតវប្បធម៌កាន់តែខ្ពស់នោះសន្ទស្សន៍ KAP ក៏កាន់តែខ្ពស់ដែរ ។ ទំនាក់ទំនងនេះត្រូវបានបញ្ជាក់នៅក្នុងការសិក្សាមួយចំនួនកាលពីអតីតកាលហើយបានគូសបញ្ជាក់អំពីសារសំខាន់នៃការអប់រំនិងវិធីដែលការអប់រំរួមចំណែកនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ពិន្ទុសន្ទស្សន៍ KAP កាន់តែទាបត្រូវបានរកឃើញនៅក្នុងចំណោមអ្នកដែលធ្វើកិច្ចការផ្ទះប៉ុន្តែគម្លាតមានកម្រិតតិចតួច។ ការផ្តោតជាគន្លឹះសម្រាប់អន្តរាគមន៍នាពេលអនាគតគួរតែធ្វើឡើងនៅតាមសាលាដែលមានសិស្សកម្រិតបឋមសិក្សា។






## សន្ទស្សន៍ KAP តាមស្ថានភាពសេដ្ឋកិច្ច

ដូចដែលបានកំណត់នៅក្នុងប្រវត្តិសេដ្ឋកិច្ចអតីតជនរងគ្រោះជាមធ្យមប្រឈមមុខនឹងកម្រិតធ្ងន់ធ្ងរនៃការលំបាកផ្នែកសេដ្ឋកិច្ចបើប្រៀបធៀបនឹងអ្នកងាយរងគ្រោះ និងជនចំណាកស្រុកដែលវិលត្រឡប់។ ពាក់ព័ន្ធនឹងអត្តសញ្ញាណក្រីក្រនិងស្ថានភាពសង្គមសេដ្ឋកិច្ចសន្ទស្សន៍KAPខ្ពស់ជាងមួយចំនួនសម្រាប់អ្នកដែលមានជីវភាពធូរធារជាង ។ ប៉ុន្តែគម្លាតមានតិចតួចណាស់ហើយបង្ហាញថាសូចនាករទាំងនេះអាចមិនមែនជាសូចនាករដែលល្អសម្រាប់ភាពងាយរងគ្រោះផ្ទាល់ឡើយ។







*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

កម្មសិទ្ធិដីធ្លីនិងភាពគ្រប់គ្រាន់នៃទិន្នផលស្រូវមានទំនាក់ទំនាក់កាន់តែខ្លាំងជាមួយសន្ទស្សន៍ KAP ហើយមានមុខងារជាសូចនាករកាន់តែប្រសើរសម្រាប់ភាពងាយរងគ្រោះដែលអាចកើតឡើង។ខណៈដែលមិនមែនជាលក្ខខណ្ឌជានាកម្មសិទ្ធិដីធ្លីអាចរួមចំណែកនៅក្នុងការរក្សាសន្តិសុខស្បៀងលុះត្រាតែទិន្នផលទទួលបានគ្រប់គ្រាន់។







*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## សន្ទស្សន៍ KAP តាមការបង្ហាញពីអំពើជួញដូរមនុស្ស

អន្តរាគមន៍លើអំពើជួញដូរមនុស្សពីមុនបានធ្វើអោយមានឥទ្ធិពលមួយចំនួនយ៉ាងជាក់ស្តែងដោយនាំមកនូវសន្ទស្សន៍ KAP រហូតដល់ប្រហែល 115-116 ។ គម្លាតនេះធំប៉ុន្តែមានកន្លែងសម្រាប់កែលម្អ ។ ប៉ុន្តែការស្គាល់អ្នកដែលបានធ្វើចំណាកស្រុកទំនងជាមិននាំអោយមានឥទ្ធិពលវិជ្ជមានឡើយ ។ ដូចដែលបានបញ្ជាក់រួចហើយបទពិសោធន៍នៃចំណាកស្រុកដោយសុវត្ថិភាពឬការជួញដូរមិននាំអោយមានការអនុវត្តចំណាកស្រុកដោយសុវត្ថិភាពដោយស្វ័យប្រវត្តិទេ។ ដោយសារជនចំណាកស្រុកជាច្រើនពឹងផ្អែកលើដំបូន្មានពីជនចំណាកស្រុកពីមុនៗ ទើបគួរតែពិចារណាលើការអប់រំជនចំណាកស្រុកពីមុនៗ ដោយសារវាអាចសម្រេចបាននូវឥទ្ធិពលបន្ទាប់បន្សំទៅលើជនចំណាកស្រុកលើកដំបូង។







*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## សន្ទស្សន៍ KAP តាមខេត្ត

ដោយពិនិត្យលើសន្ទស្សន៍ KAP នៅទូទាំងបណ្តាខេត្តពុំមានគម្លាតគ្នាខ្លាំងឡើយហើយដូច្នេះអ្នកទាំងឡាយដែលអាចនឹងព្យាយាមធ្វើចំណាកស្រុកមានកម្រិតនៃភាពងាយរងគ្រោះស្រដៀងគ្នាដោយពុំគិតពីថាតើពួកគេមកពីទីណាឡើយ ។ ការវិភាគនេះអាចអនុវត្តត្រឹមត្រូវសម្រាប់តែចំណែកអ្នកងាយរងគ្រោះ សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះដែលគំរូវិភាគតូចខ្លាំង។




*មូលដ្ឋាន៖អ្នកងាយរងគ្រោះ n=700*

## សន្ទស្សន៍ KAP តាមខេត្តវិស័យ

នៅទូទាំងវិស័យសន្ទស្សន៍ KAP ក៏មានគម្លាតតូចផងដែរ ។ ចំណែក "ផ្សេងទៀត" មានពិន្ទុខ្ពស់ជាងបន្តិចនិងរួមបញ្ចូលវិស័យនានាដូចជាដឹកជញ្ជូនហិរញ្ញវត្ថុនិងរដ្ឋាភិបាល ។ ជាថ្មីម្តងទៀតការវិភាគនេះអាចអនុវត្តត្រឹមត្រូវសម្រាប់តែចំណែកអ្នកងាយរងគ្រោះសម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់និងអតីតជនរងគ្រោះដែលគំរូវិភាគតូចខ្លាំង។




*មូលដ្ឋាន៖អ្នកងាយរងគ្រោះដែលកំពុងធ្វើការ*

◇◇◇◇◇◇◇◇◇◇◇◇

# ជំនឿស៊ុប

**ការយល់ដឹងកាន់តែស៊ីជម្រៅនិងការប្រៀបធៀបអាកប្បកិរិយារវាងក្រុមងាយរងគ្រោះ ជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះ។KAP**

## ប្រភេទមុខងារអាកប្បកិរិយាចំនួនពីរ

| បទដ្ឋានសង្គម | គុណតម្លៃផ្ទាល់ខ្លួន |
|---|---|
| "លក្ខណៈមុខមាត់ក្នុងសង្គមដែលមនុស្សចង់បាន" | "ស្ថានភាពអារម្មណ៍ដែលមនុស្សចង់បាន" |

អាកប្បកិរិយាគឺជាប្រតិកម្មអំណោយផល ឬមិនអំណោយផលចំពោះការធ្វើអន្តរាគមន៍ពិសេស ឬបញ្ហាចំបងៗដែលត្រូវដោះស្រាយ អាកប្បកិរិយាអាចវិជ្ជមាន ឬអវិជ្ជមាន ប៉ុន្តែមនុស្សតែមួយក៏អាចមានការប៉ះទង្គិច ឬមិនច្បាស់លាស់ផងដែរ មានន័យថាពួកគេនៅពេលដំណាលគ្នាមានទាំងអាកប្បកិរិយាវិជ្ជមាន និងអវិជ្ជមានចំពោះការធ្វើអន្តរាគមន៍។

មានមុខងារឥរិយាបថចំនួនពីរគឺបទដ្ឋានសង្គមនិងគុណតម្លៃផ្ទាល់ខ្លួន។ បទដ្ឋានសង្គមគឺជាប្រភេទអាកប្បកិរិយាដែលយើងបង្ហាញដើម្បីជួយបង្ហាញនូវលក្ខណៈរបស់យើងនិងដែលអាចធ្វើអោយយើងមានអារម្មណ៍ល្អព្រោះយើងបានបញ្ជាក់អំពីអត្តសញ្ញាណរបស់យើង។ ដោយសារហេតុផលនេះអាកប្ប-កិរិយារបស់យើងគឺជាផ្នែកមួយនៃអត្តសញ្ញាណរបស់យើងហើយជួយយើងអោយបានដឹងតាមរយៈការបង្ហាញអំពីអារម្មណ៍ជំនឿនិងគុណតម្លៃរបស់យើង។

មុខងារផ្សេងទៀតនៃអាកប្បកិរិយាគឺគុណតម្លៃផ្ទាល់ខ្លួន ហើយសំដៅដល់ការមានអាកប្បកិរិយាដែលការពារសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួនរបស់យើងឬដែលបញ្ជាក់ហេតុផលចំពោះសកម្មភាពដែលធ្វើអោយយើងមានអារម្មណ៍ធ្វើខុស។បុគ្គលដែលមានអាកប្បកិរិយាការពារអាចនិយាយថា៖ "ខ្ញុំមិនខ្វល់ មិនមានសារសំខាន់ចំពោះខ្ញុំទេ..."។ អាកប្បកិរិយាវិជ្ជមានចំពោះខ្លួនយើងមានមុខងារការពារនៅក្នុងការជួយយើងដើម្បីរក្សាគុណតម្លៃផ្ទាល់ខ្លួន។

គំនិតមូលដ្ឋាននៅពីក្រោយវិធីសាស្រ្តមុខងារគឺថាអាកប្បកិរិយាជួយបុគ្គលម្នាក់អោយធ្វើការសម្រុះ-សម្រួលរវាងតម្រូវការខាងក្នុងនៃការបង្ហាញផ្ទាល់ខ្លួនរបស់ពួកគេ (បទដ្ឋានសង្គម) និងការការពារ (គុណតម្លៃផ្ទាល់ខ្លួន) ។ ដោយសារកត្តានេះ លក្ខណៈនៃសារមានសារសំខាន់ព្រោះថា សារមួយអាចបង្កអោយមានកម្រិតខុសៗគ្នានៃអារម្មណ៍សម្រាប់មនុស្សខុសៗគ្នា។ដូចនេះវិធីដែលល្អសម្រាប់មនុស្សម្នាក់មិនប្រាកដថាល្អសម្រាប់មនុស្សទាំងអស់ឡើយ។

## ទំហំទិដ្ឋភាពពីរ៖បទដ្ឋានសង្គម និងគុណតម្លៃផ្ទាល់ខ្លួន

ការវាស់វែងអាកប្បកិរិយាអាចចាត់ជាទំហំទិដ្ឋភាពពីរគឺបទដ្ឋានសង្គម និងគុណតម្លៃផ្ទាល់ខ្លួន។ អា-កប្បកិរិយានៅក្នុងទំហំទិដ្ឋភាពទាំងពីរនេះអាចអវិជ្ជមាន ឬវិជ្ជមាន។ សម្រាប់ទំហំទិដ្ឋភាពបទដ្ឋានសង្គមមនុស្សអាចចាត់ថ្នាក់ថាមានបុរេវិនិច្ឆ័យ ឬភាពអត់អោនតិចឬ ច្រើន។ ចំពោះគុណតម្លៃផ្ទាល់ខ្លួន

ពាក់ព័ន្ធនឹងលក្ខណៈនៃការបដិសេធឬបើកចំហចំពោះបញ្ហា។




## ម៉ាទ្រិចជំនឿស៊ុប

ទំហំទិដ្ឋភាពទាំងពីរជួយបង្កើតម៉ាទ្រិចជំនឿស៊ុបការពិពណ៌នាក្រាហ្វិកនៃផ្នត់គំនិតទូទៅបំផុតដែលកើតមាន។ អ្នកមានមតិគាំទ្រគឺបើកចំហនិងយល់ពីអំពើជួញដូរ នៅពេលដែលអ្នកលើកលែងទោសមានលក្ខណៈផ្ទុយគ្នាស្រឡះ ។ មតិអ្នកអាណិតអាសូរមិនទំនងជាធ្វើសកម្មភាពទេ ដោយសារពួកគេក៏ស្ថិតនៅក្នុងស្ថានភាពបដិសេធដែរ។ ប៉ុន្តែអ្នករិះគន់បើកចំហ សម្រាប់ការពិភាក្សាវែកញែកតែមានមតិអវិជ្ជមានពីអំពើជួញដូរ។ គួរចំណាំថាម៉ាទ្រិចជំនឿស៊ុបមិនមែនជាផ្នែកទេ ដោយសារផ្នត់គំនិតមនុស្ស អាចបែងចែកជាធម្មជាតិទៅក្នុងចតុភាគមណ្ឌលបួន។




## លទ្ធផលម៉ាទ្រិចជំនឿស៊ុប

### អ្នកងាយរងគ្រោះ

ក្នុងចំណោមក្រុមអ្នកងាយរងគ្រោះ នៅក្នុងប្រទេសកម្ពុជា ជំនឿស៊ុបដែលទូទៅបំផុតផ្សំឡើងដោយអ្នករិះគន់តិចជាងអ្នកលើកលែងទោស។ជាថ្មីម្តងទៀត មនោសញ្ចេតនាបង្ហាញថាប្រភេទសារមិនអាចដំណើរការល្អនោះទេ ប៉ុន្តែមានលក្ខណៈប្រសើរជាងក្នុងការប្រើមធ្យោបាយផ្អែកលើភ័ស្តុតាងជាមួយនឹងអំណះអំណាងជាក់លាក់ ដែលបង្ហាញពីមូលហេតុដែលមនុស្សរងនូវហានិភ័យ និងត្រូវការពារខ្លួនរបៀបណា។



## ជនចំណាកស្រុកដែលវិលត្រឡប់

នៅក្នុងចំណោមក្រុមជនចំណាកស្រុកមានសុវត្ថិភាពក្នុងប្រទេសកម្ពុជាជំនឿស៊ុបដែលទូទៅបំផុតផ្សំឡើងដោយអ្នករិះគន់។ ជាថ្មីម្តងទៀតមនោសញ្ចេតនាបង្ហាញថាប្រភេទសារអាចមិនដំណើរការល្អនោះទេប៉ុន្តែប្រសើរជាងបើប្រើប្រាស់មធ្យោបាយផ្អែកលើភ័ស្តុតាង។ អ្នករិះគន់នឹងមានឆន្ទៈស្តាប់និងពិភាក្សាវែកញែក ប៉ុន្តែចង់ក្លាយជាអ្នកចូលរួមសកម្មនៅក្នុងការពិភាក្សាវែកញែក។




## អតីតជនរងគ្រោះ

អតីតអ្នករងគ្រោះ មានអាកប្បកិរិយាស្រដៀងគ្នានឹងក្រុមអ្នកងាយរងគ្រោះ ដែលផ្សំឡើងពីអ្នករិះគន់និងអ្នកលើកលែងទោស។ ទំហំទិដ្ឋភាពបុរេនិច្ឆ័យមានសភាពខ្លាំងក្លាហើយណែនាំថាមធ្យោបាយផ្អែកលើភ័ស្តុតាងដំណើរការបានប្រសើរបំផុត។សារធាតុនៃការបដិសេធមានសារសំខាន់ណាស់ដើម្បីការពារគុណតម្លៃផ្ទាល់ខ្លួន។ការប្រើប្រាស់អតីតជនរងគ្រោះកាលពីអតីតកាលជាអ្នកនិយាយអាចដំណើរការបានល្អ។




## គ្រប់ផ្នែកទាំងអស់

ការប្រៀបធៀបក្រុមទាំងបីនេះជាភ័ស្តុតាងបង្ហាញថាអតីតជនរងគ្រោះ បង្ហាញពីមធ្យមភាគកម្រិតនៃការបដិសេធខ្ពស់ជាងដែលមិនមានការភ្ញាក់ផ្អើលទេ ទោះបីជាពួកគេធ្លាប់ឆ្លងកាត់ក៏ដោយ ។ កត្តាកំណត់មានកម្រិតបុរេនិច្ឆ័យខ្លាំងជាង។ដូច្នេះមានតម្រូវការសម្រាប់មធ្យោបាយអនុវត្តផ្ទាល់ដើម្បីធ្វើអន្តរាគមន៍លើអំពើជួញដូរមនុស្ស។



# ការអនុវត្តយុទ្ធសាស្រ្តទំនាក់ទំនង

**អ្នកមានមតិគាំទ្រ**

មួយផ្នែកធំនៃអ្នកមានមតិគាំទ្របង្ហាញពីស្ថានភាពល្អបំផុត ដែលមានសក្តានុពលក្នុងការកសាងផ្តត់គំនិតវិជ្ជមានដែលមានស្រាប់។ មានសក្តានុពលល្អសម្រាប់ការនិយាយពីមាត់មួយទៅមាត់មួយនិងការជះឥទ្ធិពលតាមរយៈយុទ្ធនាការពីថ្នាក់ក្រោមបំផុត។មនុស្សដែលពាក់ព័ន្ធក្លាយជាដៃគូអនុវត្ត។

**អ្នករិះគន់**

ទទួលយកបញ្ហា ប៉ុន្តែនឹងបដិសេធថាមានបទដ្ឋានសង្គមដែលត្រូវឲ្យមានការគោរព។មានសារសំខាន់ក្នុងការចូលរួមក្នុងកិច្ចពិភាក្សាវែកញែកស្ថាបនានិងបដិសេធជាមួយនឹងតក្កភាព ជាជាងគំនិតមនោសញ្ចេតនា។

**អ្នកអាណិតអាសូរ**

ការដែលនៅក្នុងស្ថានភាពបដិសេធ ឬមានអារម្មណ៍ថាបញ្ហានឹងកាន់តែរីកធំរហូតដល់មិនអាចធ្វើអ្វីបាន។ការបង្ហាញមនោសញ្ចេតនានឹងដំណើរការបានល្អនៅទីនេះ ជាមួយនឹងការសង្កត់ធ្ងន់លើ "ការធ្វើបែបនេះគឺត្រឹមត្រូវ" ។ មានសារសំខាន់ក្នុងការកម្ចាត់រនាំងមានសក្តានុពលការពិត ឬស្រមើស្រមៃដើម្បីជំរុញការធ្វើសកម្មភាព។

**អ្នកលើកលែងទោស**

គឺជាក្រុមដែលទូទៅបំផុតនិងពិបាកគ្រប់គ្រងបំផុត។ផ្ទុយពីអ្នកអាណិតអាសូរការបង្ហាញមនោសញ្ចេតនា ទំនងជាមិនដំណើរការទេនៅទីនេះ ជំនួសអោយចំណុចនេះចាំបាច់អំនះអំនាងប្រកបដោយតក្កភាពនិងផ្អែកលើភ័ស្តុតាង។

◇◇◇◇◇◇◇◇◇◇◇◇◇

# ខ្សែចង្វាក់ផ្គត់ផ្គង់និងគន្លឹះបង្កហានិភ័យ

**សកម្មភាពដែលអនុវត្តឬមិនអនុវត្តដែលអាចធ្វើអោយជនចំណាកស្រុកប្រឈមនឹងហានិភ័យនៃអំពើជួញដូរ។**

## ជំហានខ្សែចង្វាក់ផ្គត់ផ្គង់

ដើម្បីកំណត់គន្លឹះបង្កហានិភ័យដែលមានសក្តានុពល ខ្សែចង្វាក់ផ្គត់ផ្គង់សម្រាប់អំពើជួញដូរមនុស្សត្រូវបំបែកជាប្រាំជំហានសំខាន់ៗ ចាប់តាំងពីពេលដែលមនុស្សម្នាក់បានដឹងពីឱកាសការងាររហូតទៅដល់ចំណុចដែលពួកគេបានទៅដល់គោលដៅ ។ ដោយបែងចែកដំណើរការ ឲ្យមានភាពងាយស្រួលសម្រាប់អតីតជនរងគ្រោះក្នុងការចងចាំ និងបង្កើតជាបរិបទនូវអ្វីដែលបានកើតឡើង ។ គួរចំណាំថា ខណៈដែលបទពិសោធន៍របស់អតីតជនរងគ្រោះអាចខុសគ្នាពីករណីមួយទៅករណីមួយទៀត ជំហានទាំងប្រាំអាចប្រើប្រាស់ជាសាមញ្ញ ជាជំនួយណែនាំដែលផ្តោតលើការពិភាក្សា លើគន្លឹះបង្កហានិភ័យសក្តានុពល និងវិសាលភាពដែលគន្លឹះបង្កអាចអនុវត្តបាននៅក្នុងករណីនីមួយៗ។ ជំហានគន្លឹះបង្កហានិភ័យត្រូវបានបង្កើតដោយផ្អែកលើអ្វីដែលបានរៀននៅពេលសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធផ្សេងៗគ្នា និងអ្នកជំនាញ ផ្នែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងដំណាក់កាល “ទិដ្ឋភាពអំពើជួញដូរ” ។




## គន្លឹះបង្កហានិភ័យសក្តានុពល

គួរចង្អុលបង្ហាញថាការវាស់វែងគន្លឹះបង្កហានិភ័យសក្តានុពលមិនគ្របដណ្តប់បានគ្រប់គន្លឹះបង្កហានិភ័យសក្តានុពលដែលមាននោះទេ ។ នៅពេលសម្ភាសន៍អតីតជនរងគ្រោះត្រូវពិចារណាពីលក្ខខណ្ឌ និងស្ថានភាពសុខភាពរបស់ពួកគេដូច្នេះហើយចាំបាច់ត្រូវធានាថាបទសម្ភាសន៍មិនមានរយៈពេលយូរពេកទេ ។ ប៉ុន្តែមានជំនឿយ៉ាងខ្លាំងក្លាថាគន្លឹះបង្កហានិភ័យសំខាន់ភាគច្រើនត្រូវបានរួមបញ្ចូលជាមួយនឹងពត៌មានលម្អិតគ្រប់គ្រាន់ដើម្បីទទួលបានរូបភាពច្បាស់លាស់នៃកត្តាហានិភ័យដែលរួមចំណែកច្រើនក្នុងអំពើជួញដូរធៀបនឹងចំណាកស្រុកប្រកបដោយសុវត្ថិភាព។

| ដំណាក់កាលខ្សែចង្វាក់ផ្គត់ផ្គង់ | គន្លឹះបង្ហាញនិភ័យសក្តានុពល |
|---|---|
| ដឹងពីឱកាសការងារ | • តើអ្នកណាប្រាប់ពួកគេ?<br>• ប្រើមេខ្យល់? |
| ស្រាវជ្រាវព័ត៌មាន | • ជួបមេខ្យល់ដោយផ្ទាល់?<br>• ប្រាប់ឈ្មោះក្រុមហ៊ុន?<br>• ស្វែងរកដំបូន្មានឯករាជ្យ?<br>• សួរសំណួរជាក់លាក់? |
| សម្រេចចិត្តថាទៅ | • សម្ភាធគ្រួសារ<br>• ធ្វើចំណាកស្រុកក្នុងស្រុកឬឆ្លងព្រំដែន<br>• ធ្វើដំណើរម្នាក់ឯង?<br>• តើអ្នកណារ៉ាប់រងថ្លៃធ្វើដំណើរ<br>• បានប្រាប់ពីថ្លៃចំណាយនានា? |
| រៀបចំការធ្វើដំណើរ | • តើអ្នកណារៀបចំការធ្វើដំណើរ?<br>• បានចុះកិច្ចសន្យា?<br>• តើពួកគេបានយកលុយមកជាមួយឬទេ?<br>• ដឹងពីប្រព័ន្ធទូរស័ព្ទបន្ទាន់ដែរឬទេ?<br>• បានទុកច្បាប់ចម្លងលិខិតឆ្លងដែន? |
| ទៅដល់គោលដៅ | • ស្ថានភាពនៅកន្លែងធ្វើការ?<br>• បង្ខំអោយបោះបង់លិខិតឆ្លងដែន?<br>• ការគំរាមគំហែង?<br>• បន្ទុកបំណុល?<br>• តាមចាប់?<br>• តើអ្នកណាជួយអោយរត់គេច? |

## តើពួកគេបានដឹងពីឱកាសការងារដោយរបៀបណា

មានភាពច្បាស់លាស់និងមិនភ្ញាក់ផ្អើលទេថា ជនជំណាកស្រុកមានសុវត្ថិភាពពឹងផ្អែកលើព័ត៌មានដែលបានមកពីសាច់ញាតិច្រើនជាងនៅពេលដែលអតីតជនរងគ្រោះអាចមានឱកាសច្រើន ក្នុងការទទួលបានព័ត៌មានពីភ្នាក់ងារឬមេខ្យល់ ។ ប៉ុន្តែមានភាពត្រួតស៊ីគ្នាហើយនេះគឺជាអ្វីដែលធ្វើអោយមានអំពើជួញដូរមនុស្ស ។វិធីមួយក្នុងការប្រឆាំងនឹងបញ្ហានេះគឺស្វែងរកដំបូន្មានឯករាជ្យ។ ដោយមិនអាចទទួលបានប្រព័ន្ធផ្សព្វផ្សាយ ឬសូម្បីតែទូរស័ព្ទចល័ត ចំណុចនេះអាចជាបញ្ហាប្រឈមសម្រាប់មនុស្សជាពិសេសប្រសិនបើអ្នកនោះមានវ័យក្មេងហើយខ្វះការអប់រំ។




*មូលដ្ឋានៈជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះ*

## ប្រើប្រាស់ភ្នាក់ងារឬមេខ្យល់

អតីតជនរងគ្រោះក៏ប្រើប្រាស់មេខ្យល់ផងដែរធៀបនឹង ២២% នៃជនចំណាកស្រុកដែលវិលត្រឡប់។ ជាថ្មីម្តងទៀតនេះមិនមែនជារឿងភ្ញាក់ផ្អើលនោះទេ ប៉ុន្តែជួយក្នុងការរំលេចនូវទស្សនៈថាអំពើជួញដូរអាចកើតឡើងទោះបីជាគ្មានមេខ្យល់ក៏ដោយ។







*មូលដ្ឋានៈបានឃើញ TIP តាមទូរទស្សន៍ក្នុងរយៈពេល ៤ សប្តាហ៍ចុងក្រោយ*

## បានជួបជាមួយមេខ្យល់

នៅក្នុងការពិនិត្យមើលឯកសារឡើងវិញ មានភស្តុតាងខ្លីៗដើម្បីណែនាំថា មេខ្យល់មិនតែងតែបង្ហាញមុខរបស់គេនោះទេហើយរស់នៅលាក់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយមានភស្តុតាងតិចតួចដើម្បីគាំទ្រមតិនេះដោយសារទាំងជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះបានជួបជាមួយមេខ្យល់នៅគ្រប់ករណីទាំងអស់ដែលមានមេខ្យល់ពាក់ព័ន្ធ។

ជនចំណាកស្រុកដែលវិលត្រឡប់




អតីតជនរងគ្រោះ




*មូលដ្ឋានៈអ្នកដែលប្រើប្រាស់មេខ្យល់*

## មេខ្យល់ដែលបានប្រាប់ឈ្មោះទីភ្នាក់ងាររបស់ខ្លួន

មេខ្យល់អាចជាជនឆបោកហើយចំណុចមួយដែលគេធ្វើនោះគឺមិនបង្ហាញឈ្មោះទីភ្នាក់ងារដែលគេធ្វើការអោយឡើយ។ក្នុងករណីជួញដូរមនុស្សការអនុវត្តបែបនេះក្លាយទៅជាលក្ខណៈប្រព័ន្ធនៅពេលដែលប្រៀបធៀបបទពិសោធនៃជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះ។ជាមធ្យោបាយជៀសវាងឈ្មោះទីភ្នាក់ងារគួរតែជាសំណួរចម្បងដែលត្រូវសួរ។

ជនចំណាកស្រុកដែលវិលត្រឡប់




អតីតជនរងគ្រោះ




*មូលដ្ឋានៈអ្នកដែលប្រើប្រាស់មេខ្យល់*

## មេខ្យល់ដែលផ្ដល់គ្រឿងលើកទឹកចិត្ត

ការសម្គាល់ដែលគួរអោយចាប់អារម្មណ៍នោះ គឺថាមិនសូវជាមានការប្រើប្រាស់គ្រឿងលើកទឹកចិត្តដោយទូលំទូលាយដូចដែលគេបានសង្ស័យនោះទេ។ មានតែអតីតជនរងគ្រោះមួយក្នុងចំណោមប្រាំនាក់ប៉ុណ្ណោះបាននិយាយថា មេខ្យល់បានផ្ដល់គ្រឿងលើកទឹកចិត្ត។ទោះជាយ៉ាងណាក៏ដោយនៅពេលមានការផ្ដល់ជាគ្រឿងលើកទឹកចិត្តអាចជាការបង្ហាញថា មេខ្យល់មិនមែនជាមនុស្សដែលគួរអោយទុកចិត្តនោះទេ។







*មូលដ្ឋាន៖អ្នកដែលប្រើប្រាស់មេខ្យល់*

## ស្វែងរកដំបូន្មានអំពីការងារ

ដូចដែលបានគូសបញ្ជាក់ពីខាងដើម ការស្វែងរកដំបូន្មានឯករាជ្យអំពីការងារគួរជាលក្ខណៈទីពីរ ប៉ុន្តែនេះមិនមែនជាករណីនោះទេ។ តិចជាងម្នាក់នៅក្នុងចំណោមអតីតជនរងគ្រោះបួននាក់បានធ្វើដូចនេះ បើធៀបនឹង ៦០% សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់។ កត្តាមួយទៀតនោះគឺ ការពឹងផ្អែកលើមិត្តភក្តិសាច់ញាតិ និងទីភ្នាក់ងារជ្រើសរើសបុគ្គលិក ។ ទាំងនេះអាចមិនមែនជាប្រភពដែលល្អបំផុតដើម្បីសួរនិងបង្ហាញថាមានតម្រូវការចាំបាច់ក្នុងការធ្វើអោយមានព័ត៌មានគួរអោយទុកចិត្តដែលអាចរកបាន។




| ប្រភពដំបូន្មាន | % |
|---|---|
| មិត្តភក្តិ & សាច់ញាតិ | 88 |
| ទីភ្នាក់ងារជ្រើសរើសបុគ្គលិក | 11 |
| មណ្ឌលចំណាកស្រុក | 1 |




| ប្រភពដំបូន្មាន | % |
|---|---|
| មិត្តភក្តិ & សាច់ញាតិ | 79 |
| ទីភ្នាក់ងារជ្រើសរើសបុគ្គលិក | 21 |
| មណ្ឌលចំណាកស្រុក | - |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់/អ្នកដែលស្វែងរកដំបូន្មាន*

## បានសួររកព័ត៌មានអំពីការងារ

ទាំងជនចំណាកស្រុកដែលវិលត្រឡប់ និងអតីតជនរងគ្រោះបានសួរព័ត៌មានអំពីការងារនៅក្នុងករណីភាគច្រើន។ ទោះជាយ៉ាងណាក៏ដោយអតីតជនរងគ្រោះសួរជាមធ្យមនូវសំណួរមួយចំនួនហើយអ្នកមួយចំនួនទៀតសួរអំពីចំនួនម៉ោងធ្វើការ និងអាសយដ្ឋានកន្លែងធ្វើការ។ខណៈដែលអ្នកជួញដូរតែងតែអាចកុហកពីព័ត៌មានបែបនេះការសួរសំណួរអាចជាការបង្អាក់ដោយសារអ្នកជួញដូរអាចត្រូវគេចាប់ថ្នាក់បាននៅពេលដែលបុគ្គលស្វែងរកដំបូន្មានឯករាជ្យ។

ជនចំណាកស្រុកដែលវិលត្រឡប់




អតីតជនរងគ្រោះ




| ព័ត៌មានដែលបានសួរ | % |
|---|---|
| ប្រាក់ខែ | 84 |
| ចំនួនម៉ោងធ្វើការ | 42 |
| លក្ខខណ្ឌការងារ | 39 |
| អាសយដ្ឋានកន្លែងធ្វើការ | 10 |

| ព័ត៌មានដែលបានសួរ | % |
|---|---|
| ប្រាក់ខែ | 53 |
| ចំនួនម៉ោងធ្វើការ | 13 |
| លក្ខខណ្ឌការងារ | 42 |
| អាសយដ្ឋានកន្លែងធ្វើការ | 12 |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ការសម្រេចចិត្តចាកចេញទៅ

គំហើញខ្លីៗមួយទៀតនៅក្នុងការពិនិត្យឯកសារឡើងវិញទាក់ទង នឹងអតីតជនរងគ្រោះដែលមានសម្ពាធគ្រួសារ ហើយក៏ធ្វើចំណាកស្រុកៗអាចជាការពិតនៅក្នុងករណីមួយចំនួន ប៉ុន្តែទិដ្ឋភាពនោះ គឺថាមនុស្សធ្វើការសម្រេចចិត្តដោយខ្លួនឯងៗដូច្នេះនៅពេលដែលសម្ពាធអាចចេញពីលក្ខខណ្ឌជីវភាពក្រីក្រ អតីតជនរងគ្រោះមិនដែលស្មានថា បញ្ហានេះកើតចេញពីគ្រួសាររបស់គេទេៗ




## ចំណាកស្រុកក្នុងប្រទេសឬឆ្លងប្រទេស

ជនចំណាកស្រុក 57 % បានធ្វើចំណាកស្រុកឆ្លងប្រទេសដែលករណីភាគច្រើនគឺទៅប្រទេសថៃ បន្ទាប់មកកូរ៉េ និងម៉ាឡេស៊ីៗ អតីតជនរងគ្រោះទាំងអស់ធ្លាប់ត្រូវបានគេជួញដូរទៅបរទេសនិងបួនក្នុងចំណោមប្រាំនាក់គឺទៅប្រទេសថៃៗគួរចំណាំថាប្រទេសជាគោលដៅដែលបានកំណត់អាចមិនមែនជាតំណាងពេញលេញនោះទេៗនៅពេលដែលអតីតជនរងគ្រោះទាំងអស់កំណត់ថាបានធ្វើចំណាកស្រុកឆ្លងប្រទេសពិបាកក្នុងការនិយាយថាអំពើជួញដូរក្នុងប្រទេសមិនកើតឡើង ៗ ប៉ុន្តែអំពើជួញដូរក្នុងប្រទេសអាចនឹងពិបាកក្នុងការកំណត់ ៗ

ជនចំណាកស្រុកដែលវិលត្រឡប់




អតីតជនរងគ្រោះ




ប្រទេសគោលដៅ

| ប្រទេស | ជនចំណាកស្រុកដែលវិលត្រឡប់ % | អតីតអ្នករងគ្រោះ % |
|---|---|---|
| ថៃ | 81 | 80 |
| កូរ៉េ | 11 | - |
| ម៉ាឡេស៊ី | 7 | 5 |
| វៀតណាម | 2 | 7 |
| ឥណ្ឌូនេស៊ី | - | 7 |
| អាហ្វ្រិកខាងត្បូង | - | 1 |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ធ្វើដំណើរជាមួយអ្នកផ្សេងទៀត

នៅក្នុងករណីភាគច្រើនជនចំណាកស្រុកដែលវិលត្រឡប់ធ្វើដំណើរជាមួយអ្នកផ្សេងទៀត ។ ក្នុងករណីអតីតជនរងគ្រោះជាង 90% បានធ្វើដំណើរជាមួយអ្នកផ្សេងទៀត។ ការធ្វើដំណើរជាក្រុមមិនសូវមានលក្ខណៈទូទៅសម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់ និងអាចធ្វើដំណើរទៅប្រទេសជិតខាងជាមួយនឹងសាច់ញាតិដោយសារមនុស្សមួយចំនួនរស់នៅជិតព្រំដែន។

ជនចំណាកស្រុកដែលវិលត្រឡប់




អតីតជនរងគ្រោះ




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ការធ្វើហិរញ្ញប្បទាននិងថ្លៃចំណាយការធ្វើដំណើរ

ជនចំណាកស្រុកដែលវិលត្រឡប់ប្រើប្រាស់លុយសន្សំផ្ទាល់ខ្លួនសម្រាប់ចំណាយក្នុងការធ្វើដំណើរច្រើនជាងអតីតជនរងគ្រោះ។ អតីតជនរងគ្រោះពឹងផ្អែកខ្លាំងលើការរ៉ាប់រងចំណាយពីភ្នាក់ងារឬត្រូវការប្រាក់កម្ចី។ចំណុចនេះរំលេចពីមធ្យោបាយទូទៅប្រើប្រាស់ដោយអ្នកជួញដូរ។ដោយអោយខ្ចីប្រាក់មុនបុគ្គលដែលត្រូវគេជួញដូរក្លាយជាពឹងផ្អែកលើអ្នកជួញដូរ។ អាស្រ័យហេតុនេះជនចំណាកស្រុកដែលវិលត្រឡប់ចំណាយជាមធ្យមលើការធ្វើដំណើរដែលមានមេដ្យាន 55 USD ធៀបនឹង 24 USD សម្រាប់អតីតជនរងគ្រោះ ។

### ការធ្វើហិរញ្ញប្បទានការធ្វើដំណើរ




### ថ្លៃចំណាយការធ្វើដំណើរ

| ថ្លៃចំណាយ | ជនចំណាកស្រុកដែលវិលត្រឡប់ USD | អតីតអ្នករងគ្រោះ USD |
|---|---|---|
| អតិបរមា | 10,000 | 338 |
| មធ្យម | 125 | 42 |
| មេដ្យាន | 55 | 24 |

*មូលដ្ឋានៈអ្នកចូលរួមទាំងអស់*

## ត្រូវបានគេប្រាប់ថា ថ្លៃចំណាយធ្វើដំណើរត្រូវសងមកវិញ

នេះអាចពន្យល់ថាហេតុអ្វីថ្លៃចំណាយការធ្វើដំណើរទាបជាងសម្រាប់អតីតជនរងគ្រោះ ។ ករណី 58% អតីតជនរងគ្រោះត្រូវបានគេប្រាប់ថាពួកគេត្រូវសងវិញនូវថ្លៃចំណាយធ្វើដំណើរធៀបនឹងករណី 21 % សម្រាប់ជនចំណាកស្រុកដែលវិលត្រឡប់។មានភាពងាយស្រួលក្នុងការមើលឃើញថាហេតុអ្វីបានជាអ្នកជួញដូរកំណត់គោលដៅចំពោះអ្នកដែលមានជីវភាពទន់ខ្សោយដោយចេញថ្លៃធ្វើដំណើរ។

### ជនចំណាកស្រុកដែលវិលត្រឡប់




### អតីតជនរងគ្រោះ




*មូលដ្ឋានៈអ្នកចូលរួមទាំងអស់*

## អនុវត្តការប្រុងប្រយ័ត្នជាមុននិងថវិកាធ្វើដំណើរ

ជនចំណាកស្រុកដែលវិលត្រឡប់ទំនងជាអនុវត្តការប្រុងប្រយ័ត្នជាមុន បើធៀបនឹងអតីតជនរងគ្រោះ ប៉ុន្តែមិនសូវជាខុសគ្នាខ្លាំងប៉ុន្មានទេ។ មានតែអតីតជនរងគ្រោះ 10% ប៉ុណ្ណោះបានចុះកិច្ចសន្យាការងារ ហើយមានតែ 5% ទេដែលបានទុកច្បាប់ចម្លងលិខិតឆ្លងដែននិង 30% បានធ្វើដំណើរឆ្លងព្រំដែនដោយមិនមានប្រាក់ទាល់តែសោះ ។ មនុស្សមួយចំនួនដឹងពីប្រព័ន្ធទូរស័ព្ទបន្ទាន់ប៉ុន្តែមានតែមនុស្សតិចតួចប៉ុណ្ណោះដែលមានទូរស័ព្ទចល័ត។ ចំណុចនេះបង្ហាញពីរបៀបដែលជនចំណាកស្រុកដែលរៀបចំមិនបានត្រឹមត្រូវហើយគឺជាគន្លឹះបង្កហានិភ័យចម្បងក្នុងការក្លាយទៅជាអ្នកដែលត្រូវគេជួញដូរ។

**អនុវត្តការប្រុងប្រយ័ត្ន**




**ថវិកាធ្វើដំណើរ**

| ថ្លៃចំណាយ | ជនចំណាកស្រុកដែលវិលត្រឡប់ % | អតីតអ្នករងគ្រោះ % |
|---|---|---|
| គ្មាន | 12 | 30 |
| តិចជាង 20$ | 36 | 27 |
| $20-50 | 29 | 30 |
| $50 ឬលើស | 23 | 13 |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## ការរៀបចំការធ្វើដំណើរ

ភាពខុសគ្នាមួយទៀតរវាងជនចំណាកស្រុកដែលវិលត្រឡប់និងអតីតជនរងគ្រោះគឺជនចំណាកស្រុកដែលវិលត្រឡប់រៀបចំការធ្វើដំណើរដោយខ្លួនឯងភាគច្រើន ។ បួននាក់ក្នុងចំណោមអតីតជនរងគ្រោះប្រាំនាក់ពឹងផ្អែកលើអ្នកដទៃអោយរៀបចំការធ្វើដំណើរអោយ ។ ការរៀបចំការធ្វើដំណើរចំណាយពេលជាមធ្យមប្រមាណ 5-6 សប្តាហ៍ចាប់តាំងពីពេលជួបមេខ្យល់ឬនិយោជក់ដំបូង។

អ្នកណារៀបចំការធ្វើដំណើរ




រយៈពេលចាប់ពីទំនាក់ទំនងលើកទី1 រហូតដល់ការធ្វើដំណើរ

| ជនចំណាកស្រុកដែលវិលត្រឡប់ មធ្យម. សប្តាហ៍ | អតីតអ្នករងគ្រោះ មធ្យម. សប្តាហ៍ |
|---|---|
| 5 | 6 |
| អតិ. 48 សប្តាហ៍ | អតិ. 30 សប្តាហ៍ |

*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## លក្ខខណ្ឌការងារនៅចំណុចគោលដៅ

ដោយសារការរៀបចំមិនត្រឹមត្រូវកើតមានចំពោះករណីចំណាកស្រុក ភាគច្រើនលក្ខខណ្ឌការងារពិតប្រាកដនៅគោលដៅចុងក្រោយ មានលក្ខណៈអាក្រក់ជាងការរំពឹងទុកសម្រាប់ករណីភាគច្រើន។ នេះជាការពិតសម្រាប់អតីតជនរងគ្រោះភាគច្រើន ហើយនៅក្នុងករណីភាគច្រើនគឺអាក្រក់ជាងការរំពឹងទុក។ ចំណុចដែលគួរអោយចាប់អារម្មណ៍នោះគឺមនុស្សមួយចំនួនផ្សាភ្ជាប់រវាងអ្វីដែលកើតឡើងចំពោះគេនឹងសកម្មភាពរបស់ខ្លួន។




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

## បទពិសោធន៍នៃការរំលោភបំពាន

ទោះបីជាជនចំណាកស្រុកដែលវិលត្រឡប់ធ្លាប់ឆ្លងកាត់ការរំលោភបំពាន (27%) ហើយក្នុងករណីភាគច្រើនគឺទាក់ទងនឹងបន្ទុកបំណុលជាធម្មតាពាក់ព័ន្ធនឹងការរៀបចំនៅជុំវិញឱកាសការងារ ។ ជាក់ស្តែងអតីតជនរងគ្រោះទាំងអស់ធ្លាប់ឆ្លងកាត់ការរំលោភបំពានរួមទាំងការគំរាមគំហែងនិងការឃុំឃាំងជាញឹកញាប់។

**ជនចំណាកស្រុកដែលវិលត្រឡប់**




**អតីតអ្នករងគ្រោះ**




*មូលដ្ឋាន៖អ្នកចូលរួមទាំងអស់*

**ប្រភេទនៃការរំលោភបំពាន**

| ការរំលោភបំពាន | ជនចំណាកស្រុកដែលវិលត្រឡប់ % | អតីតអ្នករងគ្រោះ % |
|---|---|---|
| បង្ខំអោយបោះបង់ចោលលិខិតឆ្លងដែន | 1 | 10 |
| ទទួលការគំរាមគំហែង | 7 | 63 |
| បន្ទុកបំណុល | 21 | 48 |
| តាមចាប់ខ្លួន | 7 | 77 |

| | | | | | |
|---|---|---|---|---|---|
| *លេខរៀងកំរងសំនួរ* | | | | | |
| **មណ្ឌលសង្គ្រោះ(Shelter)** | | | | | |
| *ភូមិ រឺ សហគមន៍* | | | | | |
| *ស្រុក* | | | | | |
| *ខេត្ត* | | | | | |
| *អាស័យដ្ឋាន* | | | | | |
| | | *លេខទូរស័ព្ទ* | | | |
| *កាលបរិច្ឆេទការសំភាសន៍* | __/__/2012 | *ម៉ោងផ្តើម* | | *ម៉ោងបញ្ចប់* | |
| *ឈ្មោះអ្នកសំភាសន៍* | | | | *លេខកាត* | |
| ***កំនត់ត្រានៃការត្រួតពិនិត្យ*** | | | | | |
| *អ្នកសង្កេតមើលពេលធ្វើសំភាសន៍* | | | | កាលបរិច្ឆេទ | |
| *អ្នកពិនិត្យលើកំរងសំនួរនិង* Back-check | | | | កាលបរិច្ឆេទ | |
| *មតិយោបល់* | | | | | |
| *ត្រួតពិនិត្យមើលការសំភាសន៍ដោយ* | | *រយៈពេលសំភាសន៍ ( នាទី)* | | | |

**ការបញ្ជាក់នៅតាមគោលការរបស់អង្គការអឺសូម៉ា(ESOMAR)**

ខ្ញុំសូមធានាអះអាង ថាអ្នកតបសំភាសន៏ដែលមានឈ្មោះនិងអាស័យដ្ឋាននៅក្នុងកំរងសំនួរនេះ គឺអ្នកដែលខ្ញុំមិនបានស្គាល់ពីមុនទេ។ ហើយខ្ញុំក៏ធានាដែរថាមុននឹងយកកំរងសំណួរដែលបានបំពេញរួចទៅប្រគល់ជូនអ្នកគ្រប់គ្រងក្រុម ខ្ញុំបានពិនត្យយ៉ាងល្អិតល្អន់ ដោយអនុវត្តតាមក្រិតក្រមនិង ក្រមសីលធមិរបស់អ្នកស្រាវជ្រាវ ហើយធ្វើតាមការបង្រៀនរបស់គំរោង។ ខ្ញុំឯកភាពថាព័តិមានទាំងអស់ដែល ខ្ញុំទទួលបានទាក់ទងនិងការសំភាសន៏នេះត្រូវតែត្រូវរក្សាទុកជាការសំងាត់។

| | |
|---|---|
| ចុះហត្ថលេខាដោយ | ចុះហត្ថលេខាដោយ |
| អ្នកធ្វើសំភាសន៏: ......................................./...../.... | អ្នកគ្រប់គ្រងក្រុម (supervisor)៖ ....................../...../.... |

**<u>ការណែនាំខ្លួន</u>**

ជំរាបសួរបង ខ្ញុំឈ្មោះ ......................................មកពីក្រុមហ៊ុន បី អឹម អ អេស អេស៊ា ដែលជាក្រុមហ៊ុនស្រាវជ្រាវ ទីផ្សារនិងសង្គមឯករាជ្យមួយនៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃនេះយើងខ្ញុំកំពុងធ្វើការសិក្សាមួយ ហើយយើងខ្ញុំមានបំណងឱ្យចង់អោយបងចូលរួមជាគំនិតយោបល់ ។

គំនិតយោបល់របស់បងដែលបងនឹងសំដែងចេញដើម្បីចូលរួមក្នុងការសិក្សានេះនឹងត្រូវបានរក្សាជាការសំងាត់ ។

ខ្ញុំសូមអរគុណទុកជាមុន សំរាប់ការចូលរួមរបស់បង។

**កូតា**

| **ភេទ** | | **ខេត្ត** | |
|---|---|---|---|
| ប្រុស | n=210 | ភ្នំពេញ | n=60 |
| ស្រី | n=210 | ស្វាយរៀង | n=60 |
| | | ព្រៃវែង | n=60 |
| **ប្រភេទនៃការចំណាកស្រុក** | | កោះកុង | n=60 |
| អ្នកដែលធ្វើចំណាកស្រុកហើយត្រលប់មកវិញដោយសុវត្ថិភាព - ប្រុស | n=105 | សៀមរាប | n=60 |
| អ្នកដែលធ្វើចំណាកស្រុកហើយត្រលប់មកវិញដោយសុវត្ថិភាព - ប្រុស | n=105 | បន្ទាយមានជ័យ | n=60 |
| មណ្ឌលសង្គ្រោះ - ស្រី | n=105 | កំពុងចាម | n=60 |
| សហគមន៍ - ប្រុស | n=105 | | |

S1 កត់ត្រាខេត្ត

| **ខេត្ត** | **ឈ្មោះរបស់ មណ្ឌលសង្គ្រោះ /សហគមន៍ក្នុងភូមិ** | |
|---|---|---|
| ភ្នំពេញ | | 1 |
| ស្វាយរៀង | | 2 |
| ព្រៃវែង | | 3 |
| កោះកុង | | 4 |
| សៀមរាប | | 5 |
| បន្ទាយមានជ័យ | | 6 |
| កំពុងចាម | | 7 |

S2 កត់ត្រាប្រភេទអ្នកតបសំភាសន៍

| | | |
|---|---|---|
| អ្នកដែលធ្វើចំណាកស្រុកហើយត្រលប់មកវិញដោយសុវត្ថិភាព - ប្រុស | 1 | CHECK QUOTA |
| អ្នកដែលធ្វើចំណាកស្រុកហើយត្រលប់មកវិញដោយសុវត្ថិភាព - ប្រុស | 2 | |
| មណ្ឌលសង្គ្រោះ - ស្រី | 3 | |
| សហគមន៏ - ប្រុស | 4 | |

S3 សំរាប់អ្នកដែលត្រូវបានគេជួយសង្គ្រោះពីអំពើជួញដូរ សូមកត់ត្រាកន្លែងសំភាសន៏ខាងក្រោម

| | |
|---|---|
| មណ្ឌលសង្គ្រោះ | 1 |
| សហគមន៏ | 2 |

S4 តើបងមានអាយុប៉ុន្មាន? (ចំលើយតែមួយ)

| | | |
|---|---|---|
| ក្រោម ១៤ ឆ្នាំ | 1 | **បញ្ឈប់ការសំភាសន៏** |
| ១៤ – ១៩ ឆ្នាំ | 2 | |
| ២០ – ២៤ ឆ្នាំ | 3 | |
| ២៥ – ២៩ ឆ្នាំ | 4 | |
| ៣០ ឆ្នាំរឺ ចាស់ជាងនេះ | 5 | |

S5 កាលពីបងធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស តើការងារប្រភេទណាដែលបងធ្វើនៅពេលនោះ? ចំលើយតែមួយ

| | |
|---|---|
| រោងចក្រផលិតម្ហូបអាហារ | 1 |
| រោងចក្រកាត់ដេរសំលៀកបំពាក់ | 2 |
| រោងចក្រផលិតផ្សេងទៀត | 3 |
| សំណង់ | 4 |
| នេសាទ | 5 |
| កសិកម្ម | 6 |
| ការងារផ្ទះ | 7 |
| ការងារនៅកន្លែងកំសាន្ត (មិនទាក់ទងនិងការងារផ្លូវភេទ) | 8 |
| ការងារនៅកន្លែងកំសាន្ត (ទាក់ទងនិងការងារផ្លូវភេទ) | 9 |
| សណ្ឋាគារ ភោជនីយដ្ឋាន រឺហាងការហ្វេ | 10 |
| ផ្សេងៗ | 11 |

Q1 តើមានអ្នកណាដែលបងស្គាល់ដូចជាគ្រួសារ រឺ មិត្តភិក្តជិតស្និទ្ធរបស់បងដែលធ្លាប់ធ្វើចំណាកស្រុកដើម្បីទៅធ្វើការនៅប្រទេសផ្សេងកាលពី១២ខែមុនដែររឺទេ? **(ចំលើយមានច្រើន)**

| | | |
|---|---|---|
| ទេ | 1 | **រំលងទៅ Q4** |
| ឪពុក | 2 | **បន្ត** |
| ម្តាយ | 3 | |
| បងប្អូនប្រុសរឺស្រី | 4 | |
| សាច់ញាត្តិ | 5 | |
| មិត្តភ័ក្រ្តជិតស្និទ្ធ | 6 | |
| មិត្តភ័ក្រ្តរួមការងារ | 7 | |

Q2 សព្វថ្ងៃនេះតើពួកគេនៅឯណា?(ប្រសិនបើមានមនុស្សដែលអ្នកតបសំភាសន៏ស្គាល់ច្រើនជាងមួយនាក់ដែលធ្វើចំណាកស្រុកដើម្បីទៅធ្វើការនៅក្រៅប្រទេសនោះ សូមសួរចំពោះអ្នកដែលធ្វើចំណាកស្រុកអស់រយៈពេលយូរជាងគេ)?**(ចំលើយតែមួយគត់)**

| | | |
|---|---|---|
| បានត្រលប់មកផ្ទះវិញដោយសុវត្ថិភាព | 1 | **រំលងទៅ Q4** |
| នៅតែរស់នៅក្រៅប្រទេសប៉ុន្តែនៅមានទំនាក់ទំនងមកយើងជាទៀងទាត់ | 2 | |
| នៅតែរស់នៅក្រៅប្រទេសហើយទំនាក់ទំនងមកមិនទៀងទាត់ ប៉ុន្តែពួកយើងមិនមានការព្រួយបារម្ភទេ | 3 | |
| នៅតែរស់នៅក្រៅប្រទេសហើយមិនដែលលឺដំណឹងពីពួកគេ ហើយយើងមានការព្រួយបារម្ភ | 4 | **បន្ត** |
| មិនដឹងថាពួកគេនៅកន្លែងណាទេ ហើយពួកយើងមានការព្រួយបារម្ភ | 5 | |
| យើងសង្ស័យថា ពួកគេបានបាត់ខ្លួន | 6 | |

Q3 តើបងធ្លាប់បានរាយការណ៏ពីបញ្ហានេះទៅដល់អ្នកណាម្នាក់ដែររឺទេ?**(ចំលើយតែមួយគត់)**

| | |
|---|---|
| ទេ មិនទាន់ទេ | 1 |
| បាទ/ចាស៎ បានរាយការណ៏ទៅប៉ូលីស | 2 |
| បាទ/ចាស៎ បានរាយការណ៏ទៅអង្គការ រឺ ស្ថាប័នផ្សេងៗ | 3 |

Q4 តើឯកសារអ្វីខ្លះ ដែលបងត្រូវការដើម្បីអាចទៅធ្វើការនៅក្រៅប្រទេសបាន?**(ចំលើយតែមួយគត់)**

| | |
|---|---|
| លិខិតឆ្លងដែន | 1 |
| លិខិតឆ្លងដែន និងទិដ្ឋាការ/វីសា | 2 |
| សំរាប់ប្រទេសខ្លះគឺត្រូវការទិដ្ឋាការ/វីសាសំរាប់ប្រទេសផ្សេងទៀតត្រូវការទិដ្ឋាការ/វីសា និងលិខិតអនុញ្ញាត្តិការងារ | 3 |
| លិខិតឆ្លងដែន ទិដ្ឋាការ/វីសា និងលិខិតអនុញ្ញាត្តិការងារ | 4 |

Q5 តើអាចនឹងមានអ្វីអាចកើតឡើងជាងគេ ប្រសិនបើបងទៅធ្វើការនៅប្រទេសក្រៅមួយដោយមិនមានឯកសារស្របច្បាប់?**(ចំលើយតែមួយគត់)**

| | |
|---|---|
| មិនមានរឿងអ្វីកើតឡើងទាំងអស់ | 1 |
| អ្នកមិនអាចទទួលបានប្រាក់ខែ | 2 |
| អ្នកនិងត្រូវបានចាប់ខ្លួន និងបញ្ជូនមកវិញ | 3 |
| មិនដឹង | 4 |

Q6 តើបងធ្លាប់លឺអំពី**អំពើជួញដូរមនុស្ស**ដែររឺទេ?**(ចំលើយតែមួយគត់)**

| | | |
|---|---|---|
| មិនដែលលឺអំពីវាសោះ | 1 | **រំលងទៅ K3a** |
| មិនធ្លាប់លឺច្រើនអំពីវាទេ | 2 | |
| បាទ/ចាស៎ ខ្ញុំធ្លាប់លឺអំពីវា ប៉ុន្តែខ្ញុំមិនសូវដឹងច្បាស់ជាមួយវាទេ | 3 | **បន្ត** |
| បាទ/ចាស៎ ខ្ញុំយល់ដឹងច្បាស់អំពីវា | 4 | |

Q7 តើប្រភពណាខ្លះដែលបងបានលឺអំពី **អំពើជួញដូរមនុស្ស?(ចំលើយបានច្រើន)**

| | |
|---|---|
| របាយការណ៍ព័ត៌មាន និង ប្រព័ន្ធផ្សព្វផ្សាយ | 1 |
| ឯកសារនៅក្នុងទូរទស្សន៍ រឺ កម្មវិធីនានា | 2 |
| អានសៀវភៅ | 3 |
| តាមរយៈមិត្តភ័ក្រ្ត | 4 |
| តាមរយៈអាជ្ញាធរមូលដ្ឋាន | 5 |
| អ៊ិនធឺណេត | 6 |
| ខ្សែភាពយន្ត | 7 |
| សេវាផ្សព្វផ្សាយសាធារណៈ | 8 |
| សកម្មភាពសហគមន៍ ការប្រគុំតន្ត្រី និង ព្រឹត្តិការណ៍ផ្សេងៗ ។ល។ | 9 |
| ប័ណ្ណប្រកាស ខិត្តប័ណ្ណ សៀវភៅណែនាំ | 10 |

Q8 តើបងធ្លាប់ឃើញ រឺលឺអំពីសកម្មភាពណាមួយ រឺការផ្សព្វផ្សាយណាមួយដែលផ្តោតជាក់លាក់ទៅលើ អំពើជួញដូរមនុស្ស ដែលបានធ្វើឡើងនៅក្នុងសហគមន៍របស់បងដែររឺទេ?

| | | |
|---|---|---|
| ធ្លាប់ | 1 | **បន្ត** |
| មិនធ្លាប់ រឺមិនចាំ | 2 | **រំលងទៅK1aa** |

Q9 តើមានសកម្មភាពអ្វីខ្លះ? (**ជ្រើសរើសចំលើយទាំងអស់ដែលត្រូវ**)

| | |
|---|---|
| យុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយនៅតាមទូរស្សន៍ វិទ្យុ រឺកាសែត | 1 |
| សកម្មភាពសហគមន៍ ដូចជាការប្រគុំតន្ត្រី រឺការសំដែងតាមដងផ្លូវនានា | 2 |
| ការចែកចាយនូវព័ត៌មាន ដូចជាខិតប័ណ្ណ រឺកូនសៀវភៅណែនាំ | 3 |
| កិច្ចប្រជុំសហគមន៍ សិក្ខាសាលា រឺការជួបប្រជុំនានា | 4 |
| ផ្សេងៗបើមាន........................................................................ | 5 |

Q10 តើកំរិតនៃការចូលរួមរបស់បងជាមួយនិងសកម្មភាពទាំងនេះកំរិតណាដែរ?(**ចំលើយតែមួយគត់**)

| | |
|---|---|
| គ្រាន់តែលឺវា ពីអ្នកផ្សេងប៉ុណ្ណោះ | 1 |
| ខ្ញុំបានមើល រឺ ស្តាប់វា | 2 |
| ខ្ញុំជាអ្នកចូលរួមសកម្មម្នាក់ | 3 |
| ខ្ញុំបានជួយរៀបចំ រឺ ដំណើរការសកម្មភាពទាំងនេះ | 4 |

## ចំណេះដឹង

K1aa តើប្រយោគមួយណានៅក្នុងកាតនេះដែលបងគិតថាពិពណ៌នាត្រូវបំផុតទាក់ទងនិង **អំពើជួញដូរមនុស្ស**? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| អ្នកដែលបានចាកចេញពីប្រទេសរបស់ខ្លួនហើយបានឆ្លងកាត់ព្រំដែនដោយមិនមានទិដ្ឋាការ/វីសា រឺ លិខិតឆ្លងដែន | 1 |
| អ្នកដែលបានចាកចេញពីប្រទេសរបស់ខ្លួនដោយសារការរស់នៅរបស់គាត់មានការគំរាមកំហែង | 2 |
| អ្នកដែលបានចាកចេញរឺនាំយកទៅប្រទេសផ្សេងទៀតចេញពីប្រទេសរឺសហគមរបស់ខ្លួន និងត្រូវបានគេប្រើល្បិចកលឆបោក រឺក៏បង្ខំអោយធ្វើការងារដើម្បីរកផលប្រយោជន៍អោយគេ | 3 |
| អ្នកដែលត្រូវបានគេជួយអោយបានឆ្លងដែនដោយសារអោយលុយគេ ព្រោះគាត់មិនមានឯកសារត្រឹមត្រូវ | 4 |
| មិនដឹងច្បាស់ | 5 |

K1ab តើប្រយោគមួយណានៅក្នុងកាតនេះដែលបងគិតថាពិពណ៌នាត្រូវបំផុតទាក់ទងនិង**ការរត់ពន្ធមនុស្ស**? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| អ្នកដែលបានចាកចេញពីប្រទេសរបស់ខ្លួនហើយបានឆ្លងកាត់ព្រំដែនដោយមិនមាន ទិដ្ឋាការ/វីសា រឺ លិខិតឆ្លងដែន | 1 |
| អ្នកដែលបានចាកចេញពីប្រទេសរបស់ខ្លួនដោយសារការរស់នៅរបស់គាត់មានការគំរាមកំហែង | 2 |
| អ្នកដែលបានចាកចេញរឺនាំយកទៅប្រទេសផ្សេងទៀតចេញពីប្រទេសរឺសហគមន៏របស់ខ្លួន និង ត្រូវបានគេប្រើល្បិចកលឆបោក រឺក៏បង្ខំអោយធ្វើការងារដើម្បីរកផលប្រយោជន៍អោយគេ | 3 |
| អ្នកដែលត្រូវបានគេជួយអោយបានឆ្លងដែនដោយសារអោយលុយគេ ព្រោះគាត់មិនមានឯកសារត្រឹមត្រូវ | 4 |
| មិនដឹងច្បាស់ | 5 |

K1b តើអំពើជួញដូរមនុស្សមាននៅក្នុងប្រទេសកម្ពុជាដែររឺទេ? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| ទេ អត់មានទេ | 1 |
| បាទ/ចាស៎ ប៉ុន្តែភាគច្រើនជាមួយជនរងគ្រោះដែលមកពីប្រទេសផ្សេង | 2 |
| បាទ/ចាស៎ ជាមួយជនរងគ្រោះដែលមកពីប្រទេសផ្សេងនិង ជនជាតិកម្ពុជា | 3 |
| មិនដឹងច្បាស់ | 4 |

K1c តើអំពើជួញដូរមនុស្សផ្សារភ្ជាប់ទៅ និងទ្រង់ទ្រាយឆបោក រឺការកេងប្រវ័ញ្ចប្រយោជន៍ពីអ្នកដ៏ទៃតាមបែប អ្វីមួយដូចនៅក្នុងកាតនេះ? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| បង្ខំអោយធ្វើស្ត្រីពេស្យាចារ | 1 |
| បង្ខំអោយធ្វើការដែលទាក់ទងនិង បុរស ស្ត្រី និង កុមារ | 2 |
| បង្ខំអោយធ្វើការងារដូចជាអ្នកបំរើ ។ល ។ | 3 |
| ទាំងអស់ខាងលើ | 4 |
| មិនដឹងច្បាស់ | 5 |

K1d តើអ្នកណាគេដែលជាអ្នកដែលងាយរងគ្រោះពីអំពើជួញដូរមនុស្ស? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| ស្ត្រីដែលកំពុងរកការងារធ្វើ | 1 |
| បុរសដែលកំពុងរកការងារធ្វើ | 2 |
| កុមារ | 3 |
| ទាំងអស់ខាងលើ | 4 |
| មិនដឹងច្បាស់ | 5 |

K1e តើបងដឹងថាអ្នកដែលក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយសារមូលហេតុអ្វីខ្លះ? **សូមជ្រើសរើសចំលើយមួយ**

| | |
|---|---|
| ពួកគេស្ម័គ្រចិត្តអោយគេជួញដូរ | 1 |
| ពួកគេត្រូវបានគេបោកបញ្ឆោតពីមនុស្សដែលពួកគេស្គាល់ហើយជឿជាក់ រឺតាមរយៈឱកាស ការងារដែលក្លែង ក្លាយ | 2 |
| ពួកគេត្រូវបានគេបង្ខំ | 3 |
| មិនដឹងច្បាស់ | 4 |

## ឥរិយាបថ

| | | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះៗ | ពិតជាយល់ស្រប | មិនច្បាស់ |
|---|---|---|---|---|---|---|
| A | អំពើជួញដូរមនុស្សគឺមិនមែនជាបញ្ហាធំនៅក្នុងប្រទេសកម្ពុជាទេ | 1 | 2 | 3 | 4 | 5 |
| B | អ្នកដែលខ្ញុំស្គាល់ប្រាប់ខ្ញុំថាអ្នកដែលត្រូវបានគេធ្វើការជួញដូរសាកសមទទួលបាននូវអ្វីដែលពួកគេគួរទទួល | 1 | 2 | 3 | 4 | 5 |
| C | ប្រសិនបើជនរងគ្រោះដោយសារអំពើជួញដូរមនុស្សគឺជាអ្នកដែលក្រីក្រ ដូច្នេះយ៉ាងហោចណាស់គាត់អាចទទួលបានការងារធ្វើមួយ | 1 | 2 | 3 | 4 | 5 |
| D | អ្នកដែលខ្ញុំស្គាល់មិនដែលខ្វល់ខ្វាយ អំពីបញ្ហាជួញ ដូរមនុស្សទេ | 1 | 2 | 3 | 4 | 5 |
